**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ក្របខណ្ឌគតិយុត្តសម្រាប់ការបោះផ្សាយ មូលបត្របំណុលជាសាធារណៈក្នុងបរិបទ ប្រទេសកម្ពុជា និងប្រទេសថៃ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. កែវ មុនីលាភ**

**ខ. ឃួន ម៉េងឃាង**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម ឧត្តម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **កែវ មុនីលាភ** និងខ្ញុំបាទឈ្មោះ **ឃួន ម៉េងឃាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត ក្រុម L4B2 នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២០។

**សូមសម្តែងនូវសេចក្តីគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ** ៖

**លោកឪពុក អ្នកម្តាយ** ដែលលោកទាំងទ្វេរបានបង្កើត ខិតខំពុះពារចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ និងអប់រំទូន្មានប្រៀបប្រដៅប្រកបដោយព្រហ្មវិហារធម៌ដល់រូបយើងខ្ញុំ ដែលជាបុត្រាបុត្រីរហូតដល់ធំពេញវ័យ។ នៅពេលដែលកូនចម្រើនដល់វ័យទទួលការអប់រំ លោកក៏បានបញ្ជូនកូនទៅសាលាដោយមិនគិតពីការចំណាយអ្វីទាំងអស់ គឺដើម្បីឲ្យកូនបានក្រេបជញ្ជក់នូវចំណេះដឹងដ៏មានតម្លៃដើម្បីឲ្យកូនថ្កុំថ្កើងនៅថ្ងៃអនាគត។ លោកទាំងពីរ បានខិតខំប្រឹងប្រែងទាំងកម្លាំងកាយនិងចិត្ត ដោយគ្មានពេលសម្រាក និងដោយមិនខ្លាចនឿយហត់ឡើយ។

**ឯកឧត្តមសាកលវិទ្យាធិការ លុយ ចន្ធា** លោកសាកលវិទ្យាធិការរង ព្រមទាំងលោក-លោកស្រី និងសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច គ្រប់រូបដែលតែងតែខិតខំប្រឹងប្រែងមិននឿយណាយក្នុងការផ្ទេរពុទ្ធិ និងបទពិសោធន៍ទាំងឡាយទាក់ទងទៅនឹងវិស័យច្បាប់ដល់យើងខ្ញុំទាំងពីរនាក់ ក៏ដូចជាមិត្តរួមថ្នាក់ផ្សេងទៀត។

**លោក ឃឹម ឧត្តម** ជាសាស្រ្តាចារ្យណែនាំក្នុងការស្រាវជ្រាវ និងបានផ្តល់នូវអនុសាសន៍ល្អៗជាច្រើនអនេកសម្រាប់ស្នាដៃនៃសារណាមួយនេះរហូតដល់យើងខ្ញុំអាចសម្រេចនូវកិច្ចការនេះ។ សាស្រ្តាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីជួយណែនាំ ផ្តល់ដំបូន្មានល្អៗ និងកែសម្រួលនូវរាល់ចំណុចខ្វះខាតទាំងឡាយដែលកើតមានឡើងរហូតដល់ពួកយើងទទួលបានជោគជ័យជាស្ថាពរ។

យើងខ្ញុំសូមធ្វើការឧទ្ទិសនូវស្នាដៃនេះជូនដល់បុព្វការីជន បុព្វបុរស វីរជនស្នេហាជាតិ យុទ្ធជន យុទ្ធនារី និងនិស្សិតបញ្ញាវន្តទាំងអស់ដែលបានពលីដើម្បីបុព្វហេតុជាតិ។ យើងខ្ញុំសូមគោរពជូនពរ លោក លោកស្រី អ្នកនាងកញ្ញា និងមិត្តអ្នកអាន ទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមជម្រាបសួរ និងសួស្តីលោកគ្រូ-អ្នកគ្រូ ព្រមទាំងសិស្ស-និស្សិតទាំងអស់ដែលកំពុងអានអត្ថបទសារ-ណាបញ្ចប់ការសិក្សានេះជាទីគោរពរាប់អាន។ សារណានេះ គឺជាស្នាដៃនៃការខិតខំស្រាវជ្រាវ និងរៀបរៀងឡើងដោយនិស្សិតនៃថ្នាក់L4B3 នាឆ្នាំសិក្សា **២០១៩-២០២០** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្លឹមសារដែលមាននៅក្នុងអត្ថបទដកស្រង់ដែលស្តីពី "**ក្របខណ្ឌគតិយុត្តសម្រាប់ការបោះផ្សាយមូលបត្របំណុលជាសាធារណៈក្នុងបរិបទកម្ពុជា និងថៃ**" គឺមានគោលបំណងផ្តល់ជាគតិដល់អ្នកអានគ្រប់រូបឲ្យអាចស្វែងយល់បន្ថែម អំពីក្របខណ្ឌច្បាប់ក្នុងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈទាំងក្នុងប្រទេសកម្ពុជា រួមទាំងប្រទេសថៃផងដែរ។ ខ្លឹមសារនៃអត្ថបទសារណានេះ គឺផ្តោតសំខាន់ទៅលើថា តើក្រុមហ៊ុនមួយត្រូវគោរព និងអនុវត្តតាមនូវលក្ខខណ្ឌនីតិវិធីអ្វីខ្លះ ដើម្បីអាចឱ្យក្រុមហ៊ុននោះបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបានដោយជោគជ័យ។

ទោះបីជាពួកយើងបានខិតខំសម្រិតសម្រាំងក្នុងការចងក្រងអត្ថបទសារណាមួយនេះយ៉ាងណាក៏ដោយ គឺពិតជាមានកំហុសឆ្គងជាក់ជាមិនខានទាំងពាក្យពេចន៍ អត្ថន័យ អក្ខរាវិរុទ្ធ និងទស្សនៈដែលអ្នកអាន អ្នកស្រាវជ្រាវ មិនសមស្របនឹងកើតមានឡើងក្នុងអត្ថបទនេះ។ ដូច្នេះពួកយើងទាំងពីរនាក់ ក៏សូមអភ័យទោសចំពោះកំហុសឆ្គងអចេតនាទាំងនោះជាមុន និងសូមទទួលនូវពាក្យរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកច្បាប់ លោកគ្រូ-អ្នកគ្រូ សិស្ស-និស្សិត និងមហាជនគ្រប់មជ្ឈដ្ឋានទាំងអស់ ។

ជាចុងក្រោយយើងខ្ញុំ សូមជូនពរដល់លោកគ្រូ-អ្នកគ្រូ សិស្ស-និស្សិត និងមិត្តអ្នកអានទាំងអស់ជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាក់ខានឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២០

**កែវ មុនីលាភ** និង **ឃួន ម៉េងឃាង**

# មាតិកា


ទំព័រ

**បញ្ជីពាក្យអក្សរកាត់** ........ vi

**និយមន័យនៃពាក្យបច្ចេកទេស** ........ vii

**សេចក្តីផ្តើម** ........ ០១

**ជំពូកទី ១ ៖ សញ្ញាណនៃមូលបត្របំណុល**

**ផ្នែកទី ១ ៖ សញ្ញាណនៃមូលបត្របំណុលសកល** ........ ០៣

កថាខណ្ឌទី ១ ៖ ប្រវត្តិ និងនិយមន័យនៃមូលបត្របំណុល ........ ០៣

កថាខណ្ឌទី ២ ៖ ប្រយោជន៍នៃមូលបត្របំណុលសម្រាប់សេដ្ឋកិច្ច ........ ០៤

**ផ្នែកទី ២ ៖ សញ្ញាណនៃមូលបត្របំណុលនៅប្រទេសកម្ពុជា និងប្រទេសថៃ** ........ ០៦

កថាខណ្ឌទី ១ ៖ មូលបត្របំណុលនៅប្រទេសកម្ពុជា ........ ០៦

១. ប្រវត្តិនៃការកកើត ........ ០៦

២. ប្រភេទនៃមូលបត្របំណុលតាមប្បញ្ញត្តិកម្ពុជា ........ ០៨

កថាខណ្ឌទី ២ ៖ មូលបត្របំណុលនៅប្រទេសថៃ ........ ០៨

១. ប្រវត្តិនៃការកកើត ........ ០៨

២. ប្រភេទនៃមូលបត្របំណុលតាមបទប្បញ្ញត្តិថៃ ........ ១០

**ជំពូកទី ២**

**នីតិវិធីនៃការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ**

**ផ្នែកទី ១ ៖ នីតិវិធីក្នុងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅកម្ពុជា** .... ១២

កថាខណ្ឌទី ១ ៖ លក្ខខណ្ឌនៃការធ្វើសំណើលក់មូលបត្របំណុលជាសាធារណៈ ........ ១២

១. បុគ្គលដែលអាចធ្វើសំណើបាន ........ ១២

ក. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ........ ១២

ខ. នីតិបុគ្គលប្រតិស្រុត ........ ១៣

២. សំណើលក់មូលបត្របំណុល ........ ១៣

កថាខណ្ឌទី ២ ៖ ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ........ ១៤

១. ដំណាក់កាលមុនបោះផ្សាយ ........ ១៤

ក. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុល ........ ១៤

ខ. ឯកសារស្នើសុំបោះផ្សាយ និងការដាក់ពាក្យ ........ ១៥
២. ដំណាក់កាលពេលបោះផ្សាយ ........ ១៧
ក. ការបំពេញនូវឯកសារផ្តល់ពត៌មាន ........ ១៧
ខ. ការអនុញ្ញាត និងការបដិសេធឲ្យបោះផ្សាយ ........ ១៨
គ. កម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ........ ២០
ឃ. ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ ........ ២១
ង. ការដាក់លក់មូលបត្របំណុលជាសាធារណៈ ........ ២២
ង.១. ការធ្វើបរិវិសកម្ម ........ ២២
ង.២. ការព្យួរ ឬលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ពត៌មាន ........ ២៣
៣. ដំណាក់កាលក្រោយបោះផ្សាយ ........ ២៤
កថាខណ្ឌទី ៣ ៖ ការចុះបញ្ជីលក់មូលបត្របំណុលនៅផ្សារមូលបត្របំណុលកម្ពុជា (ផ.ម.ក) ........ ២៦
១. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល ........ ២៦
២. លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ ........ ២៨
៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ ........ ៣០
**ផ្នែកទី ២ ៖ នីតិវិធីក្នុងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅថៃ** ........ ៣១
កថាខណ្ឌទី ១ ៖ សំណើលក់មូលបត្របំណុលជាសាធារណៈ ........ ៣១
កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបោះផ្សាយលក់មូលបត្របំណុលជាសធារណៈ ........ ៣២
១. ដំណាក់កាលនៃការដាក់ពាក្យ ........ ៣២
ក. លក្ខណៈនៃអ្នកដាក់ពាក្យ ........ ៣២
ខ. លក្ខខណ្ឌ និងនីតិវិធីក្នុងការដាក់ពាក្យសុំបោះផ្សាយ ........ ៣៥
២.ការដាក់សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងនៃការជូនព័ត៌មាន ........ ៣៦
ក. ទម្រង់នៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី ........ ៣៧
ខ. ការដាក់ ឬកែប្រែនូវព័ត៌មានបន្ថែម ........ ៣៧
៣. ដំណាក់កាលនៃការបោះផ្សាយ ........ ៣៨
ក. ការបដិសេធមិនឱ្យបោះផ្សាយ ........ ៣៨
ខ. ការយល់ព្រម និងការផ្សាយពាណិជ្ជកម្ម ........ ៣៩
៤. ដំណាក់កាលក្រោយបោះផ្សាយ ........ ៤១

កថាខណ្ឌទី ៣ ៖ ការចុះបញ្ជីលក់មូលបត្របំណុលជាសាធារណៈនៅប្រទេសថៃ .......................... ៤២
១. លក្ខណសម្បត្តិនៃសញ្ញាបណ្ណក្នុងការស្នើសុំចុះបញ្ជី ...................................................... ៤២
២. លក្ខខណ្ឌ និងនីតិវិធីក្នុងការចុះបញ្ជីលក់មូលបត្របំណុល .............................................. ៤២
ក. ការដាក់ពាក្យស្នើសុំ ................................................................................................... ៤២
ខ. ការពិចារណាការក្នុងការអនុញ្ញាតលើការបោះផ្សាយសញ្ញាបណ្ណ .................................. ៤៣
**សេចក្តីសន្និដ្ឋាន** .................................................................................................... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យអក្សរកាត់

- **គ.ម.ក.** ៖ គណកម្មការមូលបត្រកម្ពុជា
- **ផ.ម.ក.** ៖ ផ្សារមូលបត្រកម្ពុជា
- **SECC** (Securities and Exchange Commission of Cambodia) ៖ គណកម្មការមូលបត្រកម្ពុជា
- **CSX** (Cambodia Securities Exchange) ៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- **SEC** (Securities and Exchange Commission of Thailand) ៖ គណកម្មការមូលបត្រថៃ
- **SET** (Stock Exchange of Thailand) ៖ ផ្សារមូលបត្រថៃ
- **BoT** (Bank of Thailand) ៖ ធនាគារជាតិថៃ

# និយមន័យនៃពាក្យបច្ចេកទេស

1. **បុគ្គលបោះផ្សាយ** ៖ សំដៅដល់បុគ្គលដែលស្នើសុំ ឬបានបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។
2. **បុគ្គលធានា** (Guarantor) ៖ សំដៅដល់បុគ្គល ឬស្ថាប័ន ដែលផ្តល់ការធានាលើមូលបត្របំណុល ដោយអនុលោមទៅ តាមលក្ខខណ្ឌនៃការធានា។
3. **ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល** (Bondholders Representative) ៖ សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីធ្វើជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ស្របទៅតាមបទប្បញ្ញត្តិដែលមានជាធរមាន។
4. **ភ្នាក់ងារវាយតម្លៃលទ្ធភាពសង** (Credit Rating Agency) ៖ សំដៅដល់បុគ្គលដែឡទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីផ្តល់សេវាធ្វើចំណាត់ថ្នាក់លើបុគ្គលរងការធ្វើចំណាត់ថ្នាក់ ឬមូលបត្របំណុលដែលត្រូវបោះផ្សាយលក់។
5. **សញ្ញាបណ្ណធម្មតា** (Plain Bond) ៖ សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុននៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ ឬលក្ខណៈបន្ថែមដូច ជាសិទ្ធិទិញត្រឡប់ (Call Option) ឬសិទ្ធិលក់ (Put Option) និងមិនមានការធានា។
6. **សញ្ញាបណ្ណមានបុគ្គលធានា** (Guaranteed Bond) ៖ សំដៅដល់មូលបត្របំណុលដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមត្រូវបានទូទាត់សងដោយភាគីទីបីដែលជានីតបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។
7. **សញ្ញាបណ្ណមានវត្ថុធានា** (Secured Bond) ៖ សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។
8. **សញ្ញាបណ្ណសាជីវកម្ម** (Corporate Bond) ៖ សំដៅដល់ប្រភេទមួយនៃមូលបត្របំណុលដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានកាតព្វកិច្ចក្នុងការបង់ប្រាក់ដើម ការប្រាក់ និងកាតព្វកិច្ចផ្សេងទៀតចំពោះម្ចាស់មូលបត្របំណុល។
9. **អត្រាគូប៉ុង** (Coupon Rate) ៖ សំដៅដល់អត្រាការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់ក្នុងរយៈ ពេលនៃមូលបត្របំណុល។
10. **មូលបត្របំណុល** (Debt Securities) ៖ សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដល់បុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ខ្ចី ឬដាក់ជា

ប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី។

11. **មូលបត្រថ្មី** (New Securities) ៖ សំដៅដល់មូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ។

12. **គណៈកម្មាការមូលបត្រកម្ពុជា** (Securities and Exchange Commission of Cambodia) ៖ សំដៅដល់នីតិបុគ្គលដែលបង្កើតឡើងដើម្បីគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ។

13. **កិច្ចសន្យាធានាទិញ** (Underwriting Agreement) ៖ សំដៅដល់កិច្ចព្រមព្រៀងដែលធ្វើឡើងដើម្បីធានាទិញ មូលបត្រទាំងអស់ ឬមួយផ្នែកដែលលក់មិនអស់ តាមនីតិវិធីនៃការបរិច្ឆេទផុតកំណត់នៃសំណើលក់ជាសាធារណៈ។

# សេចក្តីផ្តើម

ហិរញ្ញប្បទាន គឺជាកម្លាំងចលករមួយដែលធានាដល់ការពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន ឬសហគ្រាសណាមួយ ព្រោះថាដើម្បីពង្រីកអាជីវកម្មមួយបានគឺត្រូវបង្កើនការផលិត ហើយដើម្បីអាចបង្កើនការផលិតបានលុះត្រាតែមាននូវប្រភពមូលធនគ្រប់គ្រាន់។ គម្រោងផែនការវិនិយោគរបស់ក្រុមហ៊ុនមួយអាចនឹងត្រូវរាំងស្ទះប្រសិនបើក្រុមហ៊ុននោះមិនមានលទ្ធភាពដើម្បីប្រមូលកៀរគរនូវប្រភពមូលធនឱ្យបានគ្រប់គ្រាន់សម្រាប់ដំណើរការការវិនិយោគនោះទេ។ ប្រភពមូលធនដែលក្រុមហ៊ុនវិនិយោគទាំងឡាយអាចរកបានគឺមានជាច្រើនប្រភេទផ្សេងៗគ្នា។ ហិរញ្ញប្បទានរបស់សហគ្រាសឯកបុគ្គល អាចកើតចេញពីការផ្តល់ឥណទានតាមរយៈកម្ចីពីធនាគារ ឬតាមរយៈការផ្តល់ឥណទានដោយសហគ្រាសដៃគូអាជីវកម្មរបស់ខ្លួនជាដើម។ ទោះជាយ៉ាងនេះក្តី ក៏ប្រភពហិរញ្ញប្បទានទាំងនោះពុំមានលក្ខណៈទូលំទូលាយ ដូចប្រភពហិរញ្ញប្បទានរបស់ក្រុមហ៊ុនពាណិជ្ជកម្មនោះទេ។ ដូច្នេះហើយ សហគ្រាស ឬក្រុមហ៊ុននីមួយៗត្រូវធ្វើការសម្រេចចិត្តឱ្យបានម៉ត់ចត់ក្នុងការជ្រើសយកមធ្យោបាយណាមួយក្នុងការរកមូលធនដើម្បីទ្រទ្រង់គម្រោងវិនិយោគរបស់ខ្លួន ដូចជាការទទួលយកសេវាហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រជាដើម។

ប្រសិនបើលើកឡើងពីហិរញ្ញប្បទានពីធនាគារ មហាជនជាទូទៅគឺប្រាកដជាបានស្គាល់ច្បាស់រួចមកហើយ ប៉ុន្តែប្រសិនបើលើកឡើងពីហិរញ្ញប្បទានពីវិស័យមូលបត្រគឺមានមនុស្សតិចតួចនៅឡើយដែលបានស្គាល់ និងស្វែងយល់ពីវិស័យមួយនេះ។ វិស័យមូលបត្រគឺជាវិស័យដ៏ថ្មីស្រឡាងមួយ ក្នុងបរិបទប្រទេសកម្ពុជាដែលវិស័យនេះនឹងផ្តល់សេវាកម្មហិរញ្ញវត្ថុដោយបំពេញទៅលើវិស័យធនាគារដែលមានស្រាប់ ហើយវាក៏នឹងផ្តល់ជាជម្រើសថ្មីមួយក្នុងការផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគនានាដោយផ្ទាល់ ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច ហើយវាក៏នឹងធ្វើឲ្យប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈកាន់តែល្អប្រសើរ និងគ្រប់ជ្រុងជ្រោយផងដែរ។

ឆ្លើយតបនឹងតម្រូវការសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលដៅរយៈពេលវែងមួយដែលទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ដោយផ្អែកលើយន្តការទីផ្សារ ដើម្បីគាំទ្រប្រកបដោយសមធម៌ និងចីរភាពនូវការកេណ្ឌប្រមូលធនធាន នូវការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងនូវកំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានធំទូលាយរឹងមាំ។ គោលនយោបាយនេះស្តែងចេញតាមរយៈការធ្វើបច្ចុប្បន្នកម្មលើឯកសារ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០" ទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥**" ។ ដើម្បីសម្រេចឲ្យបាននូវគោលនយោបាយអភិវឌ្ឍទីផ្សារនេះ សេចក្តីព្រាងច្បាប់ស្តីពី " ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០២៨ ចុះថ្ងៃទី ១៩ តុលា

ឆ្នាំ ២០០៧ ហើយសេចក្តីព្រាងច្បាប់ស្តីពី "មូលបត្ររដ្ឋ" ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី ១០ មករា ឆ្នាំ ២០០៧ ផងដែរ។ ក្រោយមកទៀតទីផ្សារមូលបត្រក៏ត្រូវបានបង្កើតឡើងដំបូងគេនៅកម្ពុជានាឆ្នាំ២០០៩ ដែលទីផ្សារមូលបត្រនេះបានក្លាយជាប្រភពហិរញ្ញប្បទានថ្មីមួយទៀតសម្រាប់ក្រុមហ៊ុនពាណិជ្ជកម្ម និងនិតីបុគ្គលប្រតិស្រុតនានា។

ដោយឡែកដោយសារតែច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងច្បាប់ស្តីពីមូលបត្ររដ្ឋ មានភាពធំទូលាយលាយពេកដោយគ្រប់ដណ្តប់ទាំងការគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រ ដែលធ្វើការជួញដូរ ឬផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ។ ដូច្នេះទើបប្រធានបទ " ក្របខណ្ឌគតិយុត្តសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈក្នុងបរិបទប្រទេសកម្ពុជា និងប្រទេសថៃ " មានគោលបំណងបកស្រាយត្រឹមការកំណត់អំពីលក្ខខណ្ឌ យន្តការ បែបបទ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយលើកយកទាំងបែបបទ និងនីតិវិធីបោះផ្សាយមូលបត្របំណុលនៅក្នុងប្រទេសកម្ពុជា រួមទាំងបែបបទ និងនីតិវិធីបោះផ្សាយមូលបត្របំណុលនៅក្នុងប្រទេសថៃ ដោយសង្ឃឹមថាវាអាចក្លាយជាឯកសារពិគ្រោះមួយសម្រាប់លើកកម្ពស់ការយល់ដឹងរបស់ សិស្ស និស្សិត និងសាធារណជនដែលមានបំណងចង់ស្វែងយល់ឲ្យកាន់តែស៊ីជម្រៅបន្ថែមទៅលើវិស័យមូលបត្រ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃមូលបត្របំណុល

## ផ្នែកទី ១ ៖ មូលបត្របំណុលសកល

ប្រសិនបើនិយាយពីប្រវត្តិដំបូង ក៏ដូចជាសញ្ញាណនៃមូលបត្របំណុលជាសាកល គឺវាមានប្រវត្តិយូរលង់ណាស់មកហើយ។ ចំណេរក្រោយមក ទើបមូលបត្របំណុលបានចាប់ផ្តើមរីកសុះសាយពាសពេញពិភពលោក បន្ទាប់ពីប្រទេសនានាបានមើលឃើញអំពីសក្តានុពលភាពនៃឧបករណ៍បំណុលប្រភេទនេះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។ សម្រាប់ប្រទេសកម្ពុជា និងប្រទេសថៃក៏មាននូវការបោះផ្សាយលក់ និងការជួញដូរមូលបត្របំណុលផងដែរ ប៉ុន្តែការឱ្យនិយមន័យ និងប្រវត្តិរបស់មូលបត្របំណុលនៃប្រទេសទាំងពីរ គឺមិនដូចគ្នានោះទេ ។

ដូច្នេះតើទាំងប្រទេសកម្ពុជា និងថៃមានប្រវត្តិ ហើយបានឱ្យនិយមន័យមូលបត្របំណុលយ៉ាងដូចម្តេច?

### កថាខណ្ឌទី ១ ៖ ប្រវត្តិ និងនិយមន័យនៃមូលបត្របំណុល

មូលបត្របំណុលមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ។ អស់រយៈពេលជាច្រើនសតវត្សរ៍ក្រោយមកការប្រើប្រាស់មូលបត្របំណុលបានរីកចម្រើនយ៉ាងខ្លាំងដោយទាំងរដ្ឋាភិបាល និងក្រុមហ៊ុននានាបានប្រើប្រាស់មូលបត្របំណុលនេះសម្រាប់ការកៀរគរស្វែងរកហិរញ្ញប្បទានបន្ថែមពីវិនិយោគិន។ សញ្ញាបណ្ណដំបូងក្នុងប្រវត្តិសាស្រ្តមានអាយុកាល ២៤០០ ឆ្នាំមុនគ.ស។ វាគឺជាដុំថ្មមួយត្រូវបានរកឃើញនៅនីពួរ (Nippur) ក្នុងរដ្ឋមេសូប៉ូតាមី (Mesopotamia) ដែលសព្វថ្ងៃជាប្រទេសអ៊ីរ៉ាក់។ កាលនោះពោតគឺជារូបិយបណ្ណនៃសញ្ញាបណ្ណ។ រហូតមកដល់ឆ្នាំ ១១០០ នៃគ.ស. ក្រុងវ៉ែនបានចាប់ផ្តើមចេញសញ្ញាបណ្ណរដ្ឋដើម្បីប្រមូលមូលនិធិគាំទ្រដល់សង្រ្គាមរបស់ខ្លួន ដែលត្រូវបានគេស្គាល់ថា Presiti។ ទីក្រុងវ៉ែនបានបន្តការអភិវឌ្ឍទីផ្សារមូលបត្របំណុលរបស់ខ្លួនពេញមួយសតវត្សរ៍ទី ១៤ ហើយប្រជាជននៅទីក្រុងនោះអាចធ្វើការទិញ-លក់និងធ្វើការជួញដូរមូលបត្របំណុលរដ្ឋនោះបាន ។ រហូតដល់ឆ្នាំ ១៦២៣ នៃគ.ស. ទើបក្រុមហ៊ុនហូឡង់-ឥណ្ឌាខាងកើតបានបោះផ្សាយនូវសញ្ញាបណ្ណសាជីវកម្មជាលើកដំបូងក្នុងប្រវត្តិសាស្រ្តជាលក្ខណៈសាធារណៈ។ ក្រោយមកទៀតនាឆ្នាំ ១៦៩៣ នៃគ.ស ទើបមានការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋជាផ្លូវការជាលើកដំបូង ដោយធនាគារជាតិអង់គ្លេសដើម្បីកៀរគរប្រមូលប្រាក់ធ្វើសង្គ្រាមទល់នឹងប្រទេសបារាំង ។

មូលបត្របំណុលត្រូវបានគេឱ្យនិយមន័យថា គឺសំដៅទៅលើឧបករណ៍បំណុលដូចជាសញ្ញាបណ្ណរដ្ឋ និងសញ្ញាប័ណ្ណសាជីវកម្មជាដើម។ សញ្ញាបណ្ណបែបនេះអាចនឹងត្រូវទិញ ឬលក់រវាងភាគីជាមួយនឹងលក្ខខណ្ឌជាមូលដ្ឋានដែលបានកំណត់ដូចជា ចំនួនទឹកប្រាក់ដែលបានខ្ចី អត្រាការប្រាក់ និងឥណប្រទិទានជាដើម។

សញ្ញាបណ្ណសាជីវកម្ម គឺជាប្រភេទនៃមូលបត្របំណុលដែលត្រូវបានចេញដោយក្រុមហ៊ុនសាជីវកម្ម (អ្នកលក់) ហើយលក់ទៅឱ្យអ្នកទិញ (វិនិយោគិន)។ ក្រុមហ៊ុនសាជីវកម្មនោះនឹងទទួលបានដើមទុនដែលខ្លួនត្រូវ

ការជាថ្នូរនឹងការបង់ការប្រាក់ជាប្រចាំទៅតាមអត្រាគូប៉ុង (Coupon Rate) ដែលបានកំណត់ជាមុនទៅឲ្យវិនិយោគិន។ នៅពេលដល់កំណត់ឥណប្រទិទាន ក្រុមហ៊ុនសាជីវកម្មនឹងត្រូវសងត្រឡប់មកវិញនូវចំនួនទឹកប្រាក់នៃដើមទុនរបស់វិនិយោគិន។ មិនសូវខុសគ្នាប៉ុន្មានពីសញ្ញាបណ្ណសាជីវកម្ម សញ្ញាបណ្ណរដ្ឋ គឺជាមូលបត្របំណុលដែលចេញដោយរដ្ឋាភិបាលដើម្បីគាំទ្រដល់ការចំណាយ និងកាតព្វកិច្ចផ្សេងៗរបស់រដ្ឋ។ សញ្ញាបណ្ណរបស់រដ្ឋាភិបាលអាចទូទាត់ការប្រាក់តាមកាលកំណត់ដែលហៅថា អត្រាគូប៉ុង។ សញ្ញាបណ្ណរបស់រដ្ឋាភិបាលដែលចេញដោយរដ្ឋាភិបាល ត្រូវបានគេចាត់ទុកថាជាការវិនិយោគដែលមានហានិភ័យទាប ព្រោះរដ្ឋាភិបាលមួយមិនងាយនឹងអាចក្ស័យធុនបានងាយៗនោះទេ ដោយសារតែវាមានហានិភ័យទាបទើបអត្រាគូប៉ុងនៃសញ្ញាបណ្ណរដ្ឋក៏ទាបទៅតាមនោះដែរ។

ខុសគ្នាពីភាគហ៊ុន សញ្ញាបណ្ណគឺមានហានិភ័យទាបជាង ហើយពេញនិយមសម្រាប់វិនិយោគិនដែលត្រូវការចំណូលថេរ ព្រោះវិនិយោគិននឹងទទួលបានការបង់គូប៉ុងជាទៀងទាត់ និងទទួលបានប្រាក់ដើមនៅពេលដល់ការកំណត់។ ចំណែកភាគហ៊ុនជាចំណែកនៃកម្មសិទ្ធិនៅក្នុងក្រុមហ៊ុន ដូច្នេះវិនិយោគិនដែលកាន់កាប់ភាគហ៊ុនអាចទទួលបានការចំណេញ និងខាតបង់អាស្រ័យលើការវិនិយោគចំណេញ ឬខាតរបស់ក្រុមហ៊ុនដែរ។ វិនិយោគិនភាគ-ហ៊ុន អាចទទួលបានអត្ថប្រយោជន៍ ប្រសិនបើក្រុមហ៊ុនមានដំណើរការល្អ ហើយតម្លៃរបស់ភាគហ៊ុនកើនឡើង។ ផ្ទុយទៅវិញ វិនិយោគិនអាចមានការខាតបង់ នៅពេលក្រុមហ៊ុនជួបការលំបាក ហើយភាគហ៊ុនអាចនឹងធ្លាក់ថ្លៃ និងក្នុងករណីអាក្រក់បំផុតក្រុមហ៊ុនអាចនឹងក្ស័យធុន។ ភាគហ៊ុនមានហានិភ័យខ្ពស់ជាងសញ្ញាបណ្ណ ក៏ប៉ុន្តែវាមានការពេញនិយមចំពោះវិនិយោគិនសម្រាប់ការវិនិយោគរយៈពេលវែង និងមានទំនោរក្នុងការផ្តល់ប្រាក់ចំណេញខ្ពស់ជាងសញ្ញាបណ្ណ ព្រមទាំងជួយដល់កំណើនសេដ្ឋកិច្ចយ៉ាងល្អប្រសើរផងដែរ។

**កថាខណ្ឌទី ២ ៖ ប្រយោជន៍នៃមូលបត្របំណុលសម្រាប់សេដ្ឋកិច្ច**

ជាទូទៅកាលណាក្រុមហ៊ុនមួយត្រូវការដើមទុន ក្រុមហ៊ុននោះក៏អាចខ្ចីប្រាក់ពីធនាគារបានដែរ ប៉ុន្តែការបោះផ្សាយលក់សញ្ញាបណ្ណគឺជាវិធីសាស្ត្រមួយដែលល្អប្រសើរជាង។ អត្រាការប្រាក់ដែលក្រុមហ៊ុនបង់ឱ្យវិនិយោគិនដែលបានទិញសញ្ញាបណ្ណជាធម្មតាគឺទាបជាងអត្រាការប្រាក់ដែលត្រូវផ្តល់ឱ្យធនាគារ។ ក្រុមហ៊ុននីមួយៗគឺរកស៊ីដើម្បីបង្កើតប្រាក់ចំណេញឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដូច្នេះការកាត់បន្ថយការប្រាក់ចំណាយច្បាស់ណាស់គឺជារឿងដែលត្រូវពិចារណាឲ្យបានម៉ត់ចត់។ នេះគឺជាមូលហេតុដែលក្រុមហ៊ុនមួយចំនួនដែលមើលទៅហាក់ដូចជាមិនត្រូវការប្រាក់សោះ ប៉ុន្តែបានបោះផ្សាយលក់សញ្ញាបណ្ណជារឿយៗ។ ការបោះផ្សាយលក់សញ្ញាបណ្ណផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនសាជីវកម្មអាចខ្ចីប្រាក់បានយ៉ាងច្រើនក្នុងអត្រាការប្រាក់ទាប ដែលកត្តានេះហើយទើបធ្វើឲ្យក្រុមហ៊ុនទាំងនោះមានសមត្ថភាពក្នុងការវិនិយោគពង្រីកអាជីវកម្មរបស់ខ្លួន និងអភិវឌ្ឍន៍គម្រោងផ្សេងទៀតជាបន្តបន្ទាប់។

ម្យ៉ាងទៀត ការបោះផ្សាយលក់សញ្ញាបណ្ណក៏ផ្តល់ឱ្យក្រុមហ៊ុននូវសេរីភាពកាន់តែច្រើនក្នុងការធ្វើប្រតិបត្តិការអាជីវកម្មផ្សេងៗដែលពួកគេត្រូវការ។ ការចេញផ្សាយលក់សញ្ញាបណ្ណធ្វើឱ្យក្រុមហ៊ុនរួចផុតពីការកម្រិតសិទ្ធិសេរីភាពទាំងឡាយដែលជាទូទៅប្រសិនបើជាកំចីពីធនាគារ វានឹងមានការរឹតត្បិតច្រើនដល់ក្រុមហ៊ុនក្នុងការធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួន។ ការរឹតត្បិតបែបនេះ គឺអាចរារាំងសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការធ្វើអាជីវកម្ម និងកំណត់ជម្រើសប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះការបោះផ្សាយលក់សញ្ញាបណ្ណនឹងធ្វើឱ្យក្រុមហ៊ុនអាចស្វែងរកហិរញ្ញប្បទានបន្ថែមបានយ៉ាងច្រើនដោយមិនចាំបាច់មានភ្ជាប់ជាមួយការរឹតត្បិតបែបនេះទេ។ ម៉្យាងវិញទៀត ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រមានលទ្ធភាពក្នុងការជ្រើសរើសថា ជាការបោះផ្សាយលក់មូលបត្របំណុលដោយមានការធានា ឬជាការបោះផ្សាយលក់មូលបត្របំណុលដោយមិនចាំបាច់មានការធានា។ ការធានានេះ អាចជាការធានាដោយដាក់តម្កល់ទ្រព្យ ឬអាចជាការធានាដោយបុគ្គល ។

សម្រាប់វិនិយោគិនការវិនិយោគលើសញ្ញាបណ្ណ គឺមានសុវត្ថិភាពជាងការយកប្រាក់ទៅវិនិយោគលើភាគហ៊ុន។ សំខាន់ភាពខុសគ្នារវាងភាគហ៊ុននិងសញ្ញាបណ្ណ គឺនៅត្រង់ថាសញ្ញាបណ្ណតំណាងឱ្យភាពជាម្ចាស់បំណុល ហើយភាគហ៊ុនតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិ។ ភាពខុសគ្នានេះហើយដែលនាំឱ្យយើងទទួលបានអត្ថ-ប្រយោជន៍ជាចម្បងនៃសញ្ញាបណ្ណ នោះគឺដោយសារតែម្ចាស់បំណុលមានអាទិភាពលើម្ចាស់ភាគហ៊ុន។ ឧទាហរណ៍ ៖ ប្រសិនបើក្រុមហ៊ុនក្ស័យធន ម្ចាស់បំណុលនឹងទទួលបានសំណងមុនអ្នកកាន់កាប់ភាគហ៊ុន។ នៅក្នុងសេណារីយ៉ូដ៏អាក្រក់នេះ យ៉ាងហោចណាស់ម្ចាស់បំណុលអាចទទួលបានប្រាក់ខ្លះត្រឡប់មកវិញ ចំណែកឯម្ចាស់ភាគហ៊ុនតែងតែត្រូវខាតបង់នូវប្រាក់វិនិយោគរបស់ខ្លួនទាំងស្រុង។

បើនិយាយពីសុវត្ថិភាពវិញ សញ្ញាបណ្ណរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក (បណ្ណរតនាគារ) ត្រូវបានគេចាត់ទុកថាគ្មានហានិភ័យ (មិនមានភាគហ៊ុនដែលគ្មានហានិភ័យនោះទេ)។ ខណៈពេលដែលមិនទទួលបានប្រាក់ចំណេញខ្ពស់ក៏ដោយ (គិតត្រឹមឆ្នាំ ២០១៨ សញ្ញាបណ្ណដែលមានរយៈពេលកំណត់ ៣០ ឆ្នាំបានផ្តល់អត្រាការប្រាក់ប្រមាណ ៣%) ប្រសិនបើវិនិយោគិនចង់រក្សាទុកដើមទុនរបស់ខ្លួនឲ្យបានល្អ ហើយទទួលការបង់អត្រាការប្រាក់ជាប្រចាំ នោះការទិញយកសញ្ញាបណ្ណពីរដ្ឋាភិបាលអាមេរិកច្បាស់ណាស់វាគឺជាជម្រើសដ៏ល្អបំផុតសម្រាប់អ្នក ព្រោះគ្មាននរណានឹងគិតទេថារដ្ឋាភិបាលរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោកមួយនេះនឹងមិនអាចមានលទ្ធភាពសងត្រឡប់មកវិញ ទាំងការប្រាក់ និងប្រាក់ដើមនោះទេ។ ទោះយ៉ាងណា ក៏ដោយត្រូវចងចាំថាទោះបីជាសញ្ញាបណ្ណមានសុវត្ថិភាពបែបនេះក៏ដោយ តែវាមិនមែនមានន័យថាមានសុវត្ថិភាពទាំងស្រុងនោះទេ។ វាក៏មានការប្រថុយប្រថានផងដែរប្រសិនបើអ្នកវិនិយោគជ្រើសយកសញ្ញាបណ្ណដែលហៅថា Junk Bonds ( Junk Bonds ជាសញ្ញាបណ្ណមួយដែលបោះផ្សាយដោយក្រុមហ៊ុនដែលមានពិន្ទុវាយតម្លៃលទ្ធភាពសងទាប ប៉ុន្តែវាផ្តល់នូវអត្រាគូប៉ុងខ្ពស់កាលណាវិនិយោគិនជឿថា ស្ថានភាពសេដ្ឋកិច្ចនឹងមានភាពល្អប្រសើរ

ឡើងនោះក្រុមហ៊ុនដែលពួកគេបានទិញសញ្ញាបណ្ណក៏នឹងមានលទ្ធភាពអាចសងត្រឡប់មកវិញនូវប្រាក់វិនិយោគរបស់ខ្លួនដែរ)។

មួយវិញទៀត ការវិនិយោគលើសញ្ញាបណ្ណក៏អាចឱ្យវិនិយោគិនព្យាករណ៍មើលអំពីប្រាក់ចំណូលរបស់ខ្លួនយ៉ាងជាក់លាក់។ វាដូចគ្នាទៅនឹងស្ថានភាពជីវិតជាក់ស្តែង មនុស្សប្រហែលជាត្រូវការសុវត្ថិភាព និងភាពដែលអាចព្យាករណ៍បាន។ ជាឧទាហរណ៍ អ្នកចូលនិវត្តន៍ច្រើនតែពឹងផ្អែកលើប្រាក់ចំណូលដែលអាចព្យាករណ៍បានដែលទទួលបានដោយវិនិយោគលើសញ្ញាបណ្ណ។ ប្រសិនបើជាការវិនិយោគលើភាគហ៊ុនវិញ ច្បាស់ណាស់ថាអ្នកអាចនឹងទទួលបានប្រាក់ចំណេញច្រើនសន្ធឹកសន្ធាប់ប្រសិនបើក្រុមហ៊ុនរបស់អ្នកមានដំណើរការល្អ តែវាប្រហែលជាគួរឲ្យសោកស្តាយ និងឈឺចាប់ណាស់ប្រសិនបើប្រាក់វិនិយោគរបស់អ្នកត្រូវបាត់បង់ក្នុងរយៈពេលត្រឹមតែ ២ ឆ្នាំបន្ទាប់។

## ផ្នែកទី ២ ៖ សញ្ញាណនៃមូលបត្របំណុលនៅប្រទេសកម្ពុជា និងប្រទេសថៃ

### កថាខណ្ឌទី ១ ៖ មូលបត្របំណុលនៅប្រទេសកម្ពុជា

#### ១. ប្រវត្តិនៃការកកើត

សម្រាប់ប្រទេសកម្ពុជាវិស័យមូលបត្រគឺជាវិស័យមួយដ៏ថ្មីមួយ ដែលទើបតែមានវត្តមានប្រហែលមួយទសវត្សចុងក្រោយនេះប៉ុណ្ណោះ ។ ពោលគឺ ក្រោយពេលដែលរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **(យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦ - ២០១៥)** ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងដើម្បីធានាការប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងបរិបទសាកលភាវូបនីយកម្មពិភពលោក។ ក្នុងយុទ្ធសាស្ត្រនេះ អាទិភាពចំពោះមុខសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា គឺការអនុម័តច្បាប់គោលស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ដូចការរំពឹងទុកមែន សេចក្តីព្រាងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ត្រូវបានរៀបចំតាក់តែងឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានឆ្លងកាត់ការពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូរអភិវឌ្ឍមកពីផ្នែកឯកជន ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ តាមរយៈការធ្វើការធ្វើសិក្ខាសាលាជាច្រើនលើក និងដៃគូអភិវឌ្ឍជាផ្លូវការដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាដើម ហើយក៏បានដកស្រង់យកបទពិសោធន៍ និងវិធានល្អៗនៃការអនុវត្តក្នុងវិស័យមូលបត្រតាមបណ្តាប្រទេសនានា ជាពិសេសប្រទេសដែលជាសមាជិកអាស៊ាន។

ក្រោយការខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាលកម្ពុជា និងជាពិសេសពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ កម្ពុជាក៏សម្រេចបានជាស្ថាពរនូវច្បាប់ស្តីពី “**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**” មួយនេះ ដែលត្រូវបានប្រកាសឲ្យប្រើដោយ **ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧**។ ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់

ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រ។ តាមរយៈច្បាប់នេះ និយ័តករវិស័យមូលបត្រមួយក៏ត្រូវបានបង្កើតឡើងគឺ **គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក.)**។ ក្រោយមកទៀតរដ្ឋាភិ-បាលកម្ពុជាក៏បានអនុម័ត **អនុក្រឹត្យលេខ ៥៤. អនក្រ.បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៩** ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន។ សញ្ញាណនៃមូលបត្របំណុលនៅក្នុងប្រទេសកម្ពុជា ក៏បានចាប់បដិសន្ធិឡើងនៅក្នុងច្បាប់ និងអនុក្រឹត្យនេះ ផងដែរ។ ប៉ុន្តែ រហូតមកដល់**ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧** ទើបគណៈកម្មការមូលបត្រកម្ពុជាបានដាក់ចេញ**ប្រកាសលេខ ០០៩/១៧ គ.ម.ក/ប្រក** ស្តីពី **"ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ"** និងបទប្បញ្ញត្តិមួយចំនួនទៀត ដើម្បីដាក់ឱ្យដំណើរការទីផ្សារមូលបត្របំណុលនៅកម្ពុជា។ ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ យន្តការ បែបបទ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យខាងលើ។ បន្ទាប់ពីទី-ផ្សារមូលបត្របំណុល ត្រូវបានដាក់ឲ្យដំណើរការរហូតមកដល់ឆ្នាំ ២០២០ នេះ មានក្រុមហ៊ុនចំនួន **៦** បានបោះផ្សាយលក់មូលបត្របំណុល ( សញ្ញាបណ្ណសាជីវកម្ម) ជាសាធារណៈ ដែលក្នុងនោះរួមមាន ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីធីត (HKL), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC), ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA), ធនាគារភ្នំពេញពាណិជ្ជម.ក( PPC Bank ), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ និងក្រុមហ៊ុន អ អិម អេ (ខេម-បូឌា)ម.ក (RMA Cambodia )។

មូលបត្របំណុលសំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ ឬដោយទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយផ្សេងទៀតដែលបានឱ្យប្រាក់ខ្ចី ឬដាក់ជាប្រាក់បញ្ញើជាមួយ បុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមនីតិវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី[1]។

សញ្ញាបណ្ណ គឺជាប្រភេទមូលបត្របំណុលដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឱ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា **"គូប៉ុង[2]"** ឬ **"ការប្រាក់"** (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា **"ឥណប្រទិទាន"**។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុនឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់នៅ

[1] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

[2] គូប៉ុង សំដៅដល់ការប្រាក់ដែលបុគ្គលបោះផ្សាយសន្យាធ្វើការទូទាត់តាមលក្ខខណ្ឌនៃមូលបត្របំណុល។ ដកស្រង់ពីប្រការ ២, លេខ ២ នៃប្រកាសស្តីពី "ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ"

ពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ, បន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។

## ២. ប្រភេទនៃមូលបត្របំណុលតាមបទប្បញ្ញត្តិកម្ពុជា

មូលបត្របំណុល ឬសញ្ញាបណ្ណចែកចេញជា **២** ប្រភេទ គឺសញ្ញាបណ្ណរដ្ឋ និងសញ្ញាបណ្ណសាជីវកម្ម។ បច្ចុប្បន្នមានតែប្រភេទសញ្ញាបណ្ណសាជីវកម្មមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅ **ផ.ម.ក** ។ **សញ្ញាបណ្ណសាជីវកម្ម** ជាប្រភេទមួយនៃមូលបត្របំណុលដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។ យោងតាមប្រកាស ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ចេញដោយ **គ.ម.ក.** សញ្ញាបណ្ណសាជីវកម្មអាចចែកចេញជា **៣** គឺ ៖

- **សញ្ញាបណ្ណធម្មតា (Plain Bonds)** សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់ឥណប្រតិទានជាមុននៅកាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ (Call Option) ឬ សិទ្ធិលក់ (Put Option) និងមិនមានការធានា។
- **សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bonds)** សំដៅដល់សញ្ញាបណ្ណដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបីដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។
- **សញ្ញាបណ្ណមានវត្ថុធានា (Secured Bonds)** សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែមូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

## កថាខណ្ឌទី ២ ៖ មូលបត្របំណុលនៅប្រទេសថៃ

### ១. ប្រវត្តិនៃការកកើត

ទីផ្សារមូលបត្របំណុលនៅក្នុងប្រទេសថៃបានចុះកាលបរិច្ឆេទកាលពីជាងមួយសតវត្សមុន ទោះបីជាល្បឿននៃការអភិវឌ្ឍន៍យ៉ាងលឿនត្រូវបានសង្កេតឃើញតែក្នុងទសវត្សចុងក្រោយ។ ការចេញមូលបត្របំណុលលើក ដំបូងរបស់ប្រទេសនេះបានកើតឡើងនៅឆ្នាំ **១៩០៣** ក្នុងរជ្ជកាលរបស់ស្តេចរាមាទី៥ **(V)**។ រាជរដ្ឋាភិបាលថៃ **(RTG)** បានផ្តល់ប័ណ្ណបំណុលរយៈពេល ៤០ ឆ្នាំដល់វិនិយោគិនអឺរ៉ុប ដែលមានចំនួនសរុបមួយលានផោនដែលពាក់កណ្តាលត្រូវបានគេដាក់នៅក្នុងទីផ្សារទីក្រុងឡុងខណៈដែលនៅសល់ដាក់នៅប៉ារីស។ ប្រាក់សញ្ញាប័ណ្ណត្រូវបានប្រើដើម្បីផ្តល់ហិរញ្ញប្បទាន ផ្លូវដែក សំណង់ និងគម្រោងឧបករណ៍ប្រើប្រាស់សាធារណៈមូលដ្ឋានដទៃទៀត។

ចាប់ពីពេលនោះមក រាជរដ្ឋាភិបាលថៃបានចេញមូលបត្របំណុលបរទេសមួយចំនួននៅក្នុងទីផ្សារអឺរ៉ុបដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេស។ ក្នុងឆ្នាំ **១៩៤៥** រដ្ឋាភិបាលបានចេញមូលបត្ររយៈពេលខ្លីជាលើកដំបូងដោយអនុញ្ញាតឲ្យធនាគារថៃបើកការដេញថ្លៃសម្រាប់វិក័យបត្ររតនាគារ។

ចំណែកឯវិស័យឯកជនវិញមិនមានភស្តុតាងបញ្ជាក់ថា នៅពេលដែលណាដែលក្រុមហ៊ុនចាប់ផ្តើមធ្វើហិរញ្ញប្បទានបំណុលតាមរយៈការចេញមូលបត្របំណុលទេ។ ទោះយ៉ាងណាច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ **១៩២៨** រួចហើយមានចែងអំពីការផ្តល់មូលបត្របំណុលក្រុមហ៊ុន។ ដូច្នេះវាត្រូវបានគេជឿថា សញ្ញាបណ្ណសាជីវ-កម្មនោះមានតាំងពីយូរយារណាស់មកហើយ។ ជាប្រវត្តិសាស្ត្រ សញ្ញាបណ្ណសាជីវកម្មត្រូវបានទាត់ចោលដោយសារតែភាពមិនពេញនិយមរបស់ខ្លួន បើប្រៀបធៀបនឹងប្រាក់កំចីធនាគារ។ កត្តាសំខាន់ដែលចូលរួមចំណែកដល់ការកំណត់ចំនួននៃសញ្ញាបណ្ណសាជីវកម្ម គឺជាច្បាប់ចាស់ដែលហាមឃាត់មិនឱ្យចេញមូលបត្របំណុលជាសាធារណៈលុះត្រាតែវាជាក្រុមហ៊ុនសាធារណៈ។ នៅពេលនោះ "ក្រុមហ៊ុនសាធារណៈ" ដែលកំណត់ដោយច្បាប់ត្រូវបានរឹតត្បិត។ ដូច្នេះគ្មានក្រុមហ៊ុនណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "ក្រុមហ៊ុនសាធារណៈ" ទេ ដូច្នេះការចេញមូលបត្របំណុលស្ទើរតែមិនបានកើតឡើងនៅក្នុងវិស័យឯកជនទេ។ មានតែសាជីវកម្មហិរញ្ញវត្ថុឧស្សាហ-កម្មនៃប្រទេសថៃ (IFCT) ដែលអាចចេញមូលបត្របំណុលបាននៅលើទីផ្សារ។ ការផ្តល់មូលបត្របំណុលដំបូងរបស់ IFCT នៅក្នុងទីផ្សារថៃបានកើតឡើងឆ្នាំ **១៩៦៨** មានទំហំត្រឹមតែ **៨០** លានបាត។ចំនួនទឹកប្រាក់ប្រចាំឆ្នាំរបស់ខ្លួនបានឈានដល់ **១០** ពាន់លានបាតកាលពីដើមឆ្នាំ **២០០០** និងជាអ្នកចេញធំជាងគេដែលមានចំនួនទឹកប្រាក់លេចធ្លោជិត **៦០** ពាន់លានបាតក្នុងឆ្នាំ **២០០២**។ ក្នុងឆ្នាំ **២០០៤** IFCT ត្រូវបានរួមបញ្ចូលគ្នាជាមួយធនាគារពាណិជ្ជកម្មពីរ ហើយក្លាយជាធនាគារពាណិជ្ជកម្មមួយ។ ក្នុងអំឡុងទសវត្ស **១៩៩០** រដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍ទីផ្សារមូលធនក្នុងស្រុក។ មូលបត្រនិងការផ្លាស់ប្តូរមូលបត្រត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ **១៩៩២** បន្ទាប់មកត្រូវបានបង្កើតគណៈកម្មាការមូលបត្រ (SEC) ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពទីផ្សារមូលធន។ ច្បាប់ពាក់ព័ន្ធត្រូវបានធ្វើវិសោធនកម្មដើម្បីឱ្យក្រុមហ៊ុនឯកជនចេញសញ្ញាបណ្ណ។ ច្បាប់ស្តីពីក្រុមហ៊ុនសាធារណៈ ក៏បានកែប្រែ ផ្លាស់ប្តូរបន្ធូរបន្ថយពីក្រុមហ៊ុនមានកម្រិតទៅជាក្រុមហ៊ុនសាធារណៈ។ ចាប់ពីដើមទសវត្សឆ្នាំ **១៩៩០** រហូតដល់វិបត្តិមុនឆ្នាំ **១៩៩៧** សេដ្ឋកិច្ចលូតលាស់បានជម្រុញតម្រូវការយ៉ាងខ្លាំងសម្រាប់ដើមទុន។ ក្រុមហ៊ុនឯកជនកាន់តែច្រើន បានជ្រើសរើសដើម្បីប្រមូលមូលនិធិពីទីផ្សារមូលបត្របំណុលក្នុងស្រុក។ ដូច្នេះ ទីផ្សារបានដំណើរការយ៉ាងសកម្ម។

នៅក្នុងវិបត្តិអាស៊ី បន្ទាប់ពីទីផ្សារមូលបត្របំណុលក្នុងស្រុកឆ្លងកាត់ការពង្រីកគួរឲ្យកត់សម្គាល់ដោយសារការកើនឡើងបរិមាណមូលបត្ររបស់រដ្ឋាភិបាល។ រដ្ឋាភិបាលត្រូវការដើមទុនថ្មីៗដើម្បីជម្រុញសេដ្ឋ-កិច្ច ដូច្នេះត្រូវចេញមូលបត្របំណុលសាធារណៈមួយចំនួនធំ។ ចាប់ពីពេលនោះមក រដ្ឋាភិបាលនៅតែបន្ត

បោះផ្សាយលក់មូលបត្របំណុលនៅលើទីផ្សារ។ នៅចុងខែសីហាឆ្នាំ ២០០៧ ភាពលេចធ្លោនៃទីផ្សារគឺប្រាក់បាត **៤.៥៦៧.២** ពាន់លានបាត ដែលជាការកើនឡើងជាង ៨ ដងពីតម្លៃលេចធ្លោ **៥៤៦,៨** ពាន់លានបាតក្នុងឆ្នាំ **១៩៩៧** ។

## ២. ប្រភេទនៃមូលបត្របំណុលតាមបទប្បញ្ញត្តិថៃ

មូលបត្របំណុល គឺជាឧបករណ៍បំណុលហិរញ្ញវត្ថុដែលតំណាងឲ្យកិច្ចព្រមព្រៀងបំណុលស្របច្បាប់រវាងម្ចាស់បំណុលនិងកូនបំណុល ដែលម្ចាស់បំណុលគឺជាអ្នកទិញឬវិនិយោគ ហើយកូនបំណុលឬអ្នកជំពាក់បំណុលគឺជាអ្នកចេញសញ្ញាបណ្ណ។ ជាថ្នូរនឹងប្រាក់កម្ចី អ្នកទិញនឹងទទួលបានការប្រាក់ ឬការបញ្ចុះតម្លៃពីតម្លៃដែលចុះលើប័ណ្ណតាមអត្រាការប្រាក់ និងពេលវេលាដែលបានបញ្ជាក់។

ជាទូទៅ លក្ខណៈសំខាន់នៃមូលបត្របំណុលរួមមាន ៖ ឈ្មោះអ្នកចេញ តម្លៃចុះលើប័ណ្ណ កាលបរិច្ឆេទ ដល់កំណត់បង់ អត្រាការប្រាក់នៃគូប៉ុង កាលបរិច្ឆេទទូទាត់ប្រាក់គូប៉ុង ប្រភេទនៃមូលបត្របំណុល និងកិច្ចព្រមព្រៀង។

មូលបត្របំណុលនៃប្រទេសថៃត្រូវបានចែកចេញជា **២** គឺ៖ សញ្ញាបណ្ណរដ្ឋ និងសញ្ញាបណ្ណសាជីវកម្ម។

- **សញ្ញាបណ្ណរដ្ឋ** ជាមូលបត្របំណុលដែលចេញដោយក្រសួងហិរញ្ញវត្ថុ ឬអង្គភាពរដ្ឋាភិបាលក្នុងគោលបំណងកៀរគរថវិកាពីស្ថាប័នសាធារណៈនិងហិរញ្ញវត្ថុទូទៅ។ ប្រទេសថៃក៏បានបែងចែកជា ៤ ផងដែរដូចជា ៖

**១. វិក័យបត្ររតនាគារ (T-Bills)** ៖ គឺជាឧបករណ៍បំណុលរយៈពេលខ្លីដែលចេញដោយក្រសួងហិរញ្ញវត្ថុ(MOF) ដែលមានកាលកំណត់តិចជាង ១ ឆ្នាំ។

**២. មូលបត្របំណុលរបស់រាជរដ្ឋាភិបាល (Government Bonds)** ៖ គឺជាឧបករណ៍បំណុលរយៈពេលមធ្យមនិងវែង។ ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមាន ២ ប្រភេទគឺ ៖ សញ្ញាប័ណ្ណកម្ចី (LB) និងសញ្ញា-ប័ណ្ណសន្សំ (SB) ។ សញ្ញាប័ណ្ណកម្ចី (LBs) មានកាលកំណត់ចន្លោះពី ១ ឆ្នាំទៅ ៥០ ឆ្នាំ។ ខណៈពេលដែលសញ្ញាប័ណ្ណកម្ចី (LBs) ត្រូវបានចេញសម្រាប់ការផ្តល់ហិរញ្ញប្បទានឱនភាពថវិកា និងការរៀបចំរចនាសម្ព័ន្ធបំណុលរដ្ឋាភិបាល សញ្ញាប័ណ្ណសន្សំត្រូវបានចេញដើម្បីផ្តល់ឱ្យគ្រួសារនូវប្រភពសន្សំជំនួស។

**៣. វិក័យបត្រ និងមូលបត្របំណុលនៃធនាគារថៃ (BoT)** ៖ ត្រូវបានចេញដោយធនាគារកណ្តាលដែលជាផ្នែកមួយនៃប្រតិបត្តិការទីផ្សារប្រាក់។ លក្ខខណ្ឌគឺ តិចជាង ១ ឆ្នាំសម្រាប់វិក័យប័ត្រ និងរហូតដល់ ៣ ឆ្នាំសម្រាប់ប័ណ្ណបំណុល។

៤. មូលបត្របំណុលសហគ្រាស (SOE) ៖ គឺជាឧបករណ៍បំណុលរយៈពេលមធ្យម និងវែងដែលចេញដោយសហគ្រាសគ្រប់គ្រងដោយរដ្ឋ។ ទាំងនេះអាចត្រូវបានចែកជា ២ ប្រភេទគឺ ធានាដោយក្រសួងហិរញ្ញវត្ថុ និងមិនមានការធានា។ មូលបត្របំណុលដែលមានការធានា មានប្រមាណជា ៧០% នៃចំនួនប័ណ្ណសរុប។

- **សញ្ញាបណ្ណសាជីវកម្ម** គឺឧបករណ៍បំណុលដែលចេញដោយវិស័យឯកជន។ សញ្ញាបណ្ណសាជីវកម្មស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការមូលបត្រ (SEC)។ សញ្ញាបណ្ណសាជីវកម្មរួមមាន ៖

១. **សញ្ញាបណ្ណសាជីវកម្មរយៈពេលវែង** គឺសញ្ញាប័ណ្ណសាជីវកម្មរយៈពេលវែងដែលជាមូលបត្របំណុលដែលចេញដោយវិស័យសាជីវកម្មជាមួយភតិកៈចាប់ពី ១ ឆ្នាំឡើងទៅ។ ដែលអាចត្រូវបានចាត់ថ្នាក់តាមប្រភេទគូប៉ុងដូចខាងក្រោមៈ

- ➢ មូលបត្របំណុលអត្រាការប្រាក់ថេរ ៖ មូលបត្រសាជីវកម្មភាគច្រើនចាត់ចូលក្នុងប្រភេទនេះ។ ក្នុងឆ្នាំ ២០០៦, **៩៣%** នៃមូលបត្រសាជីវកម្មត្រូវបានចុះបញ្ជីជាមួយ Thai BMA ត្រូវបានកែនូវអត្រាការប្រាក់នៃមូលបត្របំណុល។ ការចេញកាលកំណត់ចាប់ពី **១ឆ្នាំ** ទៅដល់ **១០ឆ្នាំ** ប៉ុន្តែភាគច្រើនគឺស្ថិតនៅចន្លោះ **៥ឆ្នាំ**។ មូលបត្របំណុលអាចចេញដោយមាន ឬគ្មានការធានា។ មួយចំនួនត្រូវបានធានាដោយវត្ថុបញ្ចាំដូចជាទ្រព្យសម្បត្តិ។
- ➢ មូលបត្របំណុលអត្រាការប្រាក់អណ្តែត ៖ ប្រភេទនៃអត្រាការប្រាក់ត្រូវបានប្រើជាឯកសារយោងដូចជាអត្រាផ្តល់ប្រាក់កម្ចីអប្បបរមារបស់ធនាគារពាណិជ្ជកម្ម អត្រាប្រាក់បញ្ញើនៅធនាគារ និងអត្រាការប្រាក់ថេររបស់ថៃ...។ល។
- ➢ មូលបត្របំណុលដែលអាចប្តូរបាន

២. **ក្រដាសពាណិជ្ជកម្ម (CPs)** ដែលជាឧបករណ៍បំណុលរយៈពេលខ្លីរួមទាំង **Bes** និង **Debenture**។ វាជាធម្មតា ក្រដាសពាណិជ្ជកម្មមានកាលកំណត់តិចជាង **270 ថ្ងៃ**។

**៣. មូលបត្របំណុលបរទេស ៖** ចាប់តាំងពីឆ្នាំ ២០០៥ មក ក្រសួងហិរញ្ញវត្ថុបានអនុញ្ញាតឱ្យស្ថាប័នបរទេសមួយចំនួនចេញប័ណ្ណបំណុលជាប្រាក់បាតនៅក្នុងប្រទេសថៃ។ ពួកគេរួមបញ្ចូលទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិរដ្ឋាភិបាលបរទេសស្ថាប័នហិរញ្ញវត្ថុនៃរដ្ឋាភិបាលបរទេស និងអង្គភាពបរទេស។ ឧទាហរណ៍៖ ធនាគារអភិវឌ្ឍន៍អាស៊ីធនាគារជប៉ុនសម្រាប់កិច្ចសហ-ប្រតិបត្តិការអន្តរជាតិ និងរោមសត្វ Kreditansalt វីដ្រាវ៉ាហ្វូបា (KfW) ។

**៤. សញ្ញាប័ណ្ណកម្ចីបរទេស - បរទេស ៖** នៅឆ្នាំ ២០១០ អង្គភាពថៃត្រូវបានអនុញ្ញាតឱ្យចេញមូលបត្របំណុលជារូបិយប័ណ្ណបរទេស។ បច្ចុប្បន្ននេះ មានតែក្រុមហ៊ុនមួយទេដែលចេញប័ណ្ណប្រភេទនេះ។

# ជំពូកទី ២
# នីតិវិធីក្នុងការបោះផ្សាយមូលបត្របំណុលនៅកម្ពុជា និងថៃ

ដើម្បីអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបាន បុគ្គលដែលមានបំណងចង់បោះផ្សាយត្រូវតែបំពេញ តាមលក្ខខណ្ឌ និងនីតិវិធីទាំងឡាយដែលបានកំណត់នៅក្នុងច្បាប់ ក៏ដូចជាបទប្បញ្ញត្តិនានាដែលកំពុងចូលជាធរមាន រួមទាំងសេចក្តីណែនាំរបស់គណកម្មាការមូលបត្រផងដែរ។

តើសម្រាប់បរិបទក្នុងប្រទេសកម្ពុជា និងបរិបទក្នុងប្រទេសថៃមានការកំណត់ពីលក្ខខណ្ឌ និងនីតិវិធីក្នុងការបោះផ្សាយមូលបត្របំណុលយ៉ាងដូចម្តេចខ្លះ?

## ផ្នែកទី ១ ៖ នីតិវិធីក្នុងការបោះផ្សាយមូលបត្របំណុលនៅកម្ពុជា

### កថាខណ្ឌទី ១ ៖ សំណើលក់មូលបត្របំណុលជាសាធារណៈ

មូលបត្របំណុល ជាប្រភេទមូលបត្រដែលស្ថិតនៅក្នុងមូលបត្រមហាជន។ តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក្នុងមាត្រា ១២ បានចែងថា "គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះបានទទួលការអនុញ្ញាតពី **គ.ម.ក** ដោយអនុលោមតាមច្បាប់ និងលក្ខខណ្ឌផ្សេងៗដែលកំណត់ដោយ **គ.ម.ក**។ បុគ្គលនោះត្រូវបង់ថ្លៃសេវាដាក់ពាក្យសុំ ដែលកំណត់ឡើងស្របតាមច្បាប់នេះ។

#### ១. បុគ្គលដែលអាចធ្វើសំណើបាន

មានតែនីតិបុគ្គលតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើលក់មូលបត្រជាសាធារណៈបាន។ ដោយយោងតាមមាត្រា ១៦ ចំណុចទី ១ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន បានចែងថា " មូលបត្រដែលអាចត្រូវធ្វើសំណើលក់ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុតដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន" ។ ទោះបីជាមានតែនីតិបុគ្គលប៉ុណ្ណោះដែលអាចមានសិទ្ធិបោះផ្សាយលក់មូលបត្រជាសាធារណៈបានក៏ដោយ ក៏មិនមែនមានន័យថាគ្រប់នីតិបុគ្គលទាំងអស់សុទ្ធតែអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបាននោះទេ។ ពោលគឺមានតែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុតទេ ដែលអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបាន ដោយត្រូវទទួលបានការអនុញ្ញាតជាមុនពីគណៈកម្មាការមូលបត្រកម្ពុជា។

##### ក. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

យោងតាមសន្ទានុក្រមក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនបានឱ្យនិយមន័យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ថាជាក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រ។ បើយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

វិញ ក្នុងមាត្រា ៨៧ បានចែងថា " ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះផ្សាយនូវមូលបត្រដែល អាចដាក់លក់ជាសាធារណៈបាន[3]។ ច្បាប់នេះអនុញ្ញាតឲ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មានសិទ្ធិបោះផ្សាយលក់មូលបត្រដោយសេរី ព្រោះមូលបត្រជាប្រភេទប័ណ្ណដែលអាចផ្ទេរបានដោយសេរីដោយវាស្របទៅនឹងចរិតលក្ខណៈរបស់ក្រុមហ៊ុន ដែលជាប្រភេទក្រុមហ៊ុនមូលធនសុទ្ធសាធ ហើយអាចផ្ទេរភាគហ៊ុនបានដោយសេរី។ ក្រៅពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នីតិបុគ្គលប្រតិស្រុតក៏អាចបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ។

### ខ. នីតិបុគ្គលប្រតិស្រុត

ដើម្បីជំរុញឱ្យទីផ្សារមូលបត្រ អាចដំណើរការដោយមានការចូលរួមចំណែកពីក្រុមហ៊ុនបោះផ្សាយច្រើន ក្រៅពីអនុញ្ញាតឲ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចបោះផ្សាយលក់មូលបត្រជាសាធារណៈបាន យោងតាមមាត្រា ១៦ ចំណុចទី ១ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក៏បានអនុញ្ញាតឲ្យនីតិបុគ្គលប្រតិស្រុតអាចធ្វើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈផងដែរ។

នីតិបុគ្គលប្រតិស្រុត គឺជានីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងបញ្ញត្តិផ្សេងៗ។

នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជាឡើយ (សន្ទានុក្រមសម្រាប់ប្រើក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន)។ នីតិបុគ្គលប្រតិស្រុតអាចជាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកផ្សេងទៀតដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតជាដើម។ ប៉ុន្តែដោយសារតែ មានការហាមឃាត់នូវលទ្ធភាពបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ស្របតាមមាត្រា ៤៧ និងមាត្រា ៨៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ដូចនេះនីតិបុគ្គលប្រតិស្រុតជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតរបស់បរទេសហើយមានបំណងចង់បោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងទីផ្សារមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. សំណើលក់មូលបត្របំណុល

បច្ចុប្បន្ន មូលបត្របំណុលដែលត្រូវធ្វើសំណើលក់ជាសាធារណៈបាន គឺសំដៅដល់សញ្ញាបណ្ណសាជីវកម្មដែលរួមមានសញ្ញាបណ្ណធម្មតា សញ្ញាបណ្ណមានវត្ថុធានា និងសញ្ញាបណ្ណមានបុគ្គលធានា។ សំណើលក់សញ្ញាបណ្ណសាជីវកម្មប្រភេទផ្សេងទៀតដូចជា សញ្ញាបណ្ណបរិវត្ត និងសញ្ញាបណ្ណដទៃទៀតជាដើម ត្រូវអនុវត្ត

[3] មាត្រា ៨៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

តាមលក្ខខណ្ឌផ្សេងទៀតក្នុងបទប្បញ្ញត្តិដោយឡែក និងត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃគណៈ-កម្មការមូលបត្រកម្ពុជា។

មូលបត្របំណុលដែលធ្វើសំណើលក់ ត្រូវមាន[4] ៖

- អត្តសញ្ញាណរបស់បុគ្គលបោះផ្សាយ
- តម្លៃចារឹក
- អត្រាគូប៉ុង ឬមិនមានអត្រាគូប៉ុងក្នុងករណីមូលបត្របំណុលបោះផ្សាយលក់ក្នុងតម្លៃអប្បរមា
- កាលបរិច្ឆេទនៃការបោះផ្សាយលក់មូលបត្របំណុល
- ឥណប្រទិទាន។

## កថាខណ្ឌទី ២ ៖ ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

### ១. ដំណាក់កាលមុនបោះផ្សាយ

#### ក. លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយ

ដើម្បីអាចបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបាន បុគ្គលដែលមានបំណងចង់បោះផ្សាយត្រូវដាក់ពាក្យស្នើសុំជាមុនដោយត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម[5]៖

- ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត
- មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធា-រណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។
- មានរបាយកាណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវធ្វើសវនកម្មតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណា-ចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធាណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។
- មានកម្រិតអភិបាលកិច្ចសាជីវកម្មរឹងមាំ ដោយមានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់។
- ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ។

[4] ប្រការ ៤ នៃប្រកាសស្តីពី ការបោះផ្សាយមូលបត្របំណុលជាសាធារណៈ

[5] ប្រការ ៦ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

- ទទួលបានការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីមូលបត្របំណុល និងការដាក់តម្លៃមូលបត្របំណុលពីទីផ្សារមូលបត្រប្រតិស្រុត។

ក្នុងករណីការបោះផ្សាយនោះជាការបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលដាក់ពាក្យសុំត្រូវបំពេញលក្ខខណ្ឌទាំង ៦ ដូចចំណុចខាងលើ និងបំពេញបន្ថែមចំនួន **២** ចំណុចទៀតគឺ[6] ៖

១. មានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រតិភោគណាមួយឡើយ។ ករណីវត្ថុធានាជាអចលនវត្ថុ ឬសិទ្ធិជួលអចិន្ត្រៃយ៍ តម្លៃនៃវត្ថុធានានោះត្រូវវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការស្គាល់ពី **គ.ម.ក.**។

២. ចំពោះចំនួនទឹកប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈត្រូវមានតម្លៃអតិបរិមាស្មើនឹង ៧០ (ចិតសិប) ភាគរយនៃតម្លៃវត្ថុធានា គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

ក្នុងករណីការបោះផ្សាយនោះជាការបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលដាក់ពាក្យសុំត្រូវបំពេញលក្ខខណ្ឌដូចខាងលើ លើកលែងតែលេខ ៥ និងបំពេញបន្ថែមចំនួន **១** ចំណុចទៀតគឺ[7] ៖ ត្រូវមានបុគ្គលធានាដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ហើយបុគ្គលធានានោះត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

### ខ. ឯកសារស្នើសុំបោះផ្សាយ និងការដាក់ពាក្យ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈត្រូវដាក់ពាក្យស្នើសុំ ដើម្បីសុំការអនុញ្ញាតលើសំណើបោះផ្សាយ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន[8]។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានដូចតទៅ[9] ៖

១. ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២. ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.** ។

៣. ឯកសារភ្ជាប់។

សម្រាប់ឯកសារភ្ជាប់ដែលតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំភ្ជាប់ជាមួយនឹងពាក្យស្នើសុំមានដូចជា :

ក. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ. លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

---

[6] ប្រការ ៧ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[7] ប្រការ ៨ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[8] ប្រការ ១១ កថាខណ្ឌទី ១ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[9] ប្រការ ១០ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ឃ. លិខិតប្រគល់សិទ្ធិឲ្យអភិបាល ឬនាយកប្រតិបត្តិនៃបុគ្គលបោះផ្សាយ ដែលចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

ង. លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ច. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញ ដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ក្នុងករណីរបាយ ការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ៦ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មដែលមិនមានការទទួលស្គាល់ពី **គ.ម.ក** ។

ឆ. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ

ជ. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ពី **គ.ម.ក**

ឈ. របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី**គ.ម.ក**

ញ. កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ ដែលមាន

ដ. កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនមាន

ឋ. កិច្ចសន្យាធានាទិញ ឬគ្រោងចុះកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនធានាទិញមូលបត្រថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ

ឌ. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ

ឍ. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ

ណ. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ត. ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ

ថ. ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម ៖

ថ.១- ភ័ស្តុតាងអំពីវត្ថុធានា

ថ.២- វិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាបើប្រាតិភោគណាមួយឡើយ។

ថ.៣- របាយការណ៍ស្តីពីការវាយតម្លៃទ្រព្យសកម្មដែលចេញដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក**។

ទ. ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោមៈ

ទ.១- របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារ វាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក** ។

ទ.២- កិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

ធ. ឯកសារផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក** ។

## ២. ដំណាក់កាលពេលបោះផ្សាយ

### ក. ការបំពេញនូវឯកសារផ្តល់ពត៌មាន

ដើម្បីអាចធ្វើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបាន បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវដាក់ពាក្យស្នើសុំ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលជាឯកសារដ៏ចាំបាច់ក្នុងការផ្តល់ព័ត៌មានលម្អិតអំពីក្រុមហ៊ុនដែលមានបំណងបោះផ្សាយដល់សាធារណជន។

ឯកសារផ្តល់ពត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិ និងនាយកហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំ។ ឯកសារផ្តល់ពត៌មានត្រូវមានមាតិការអប្បបរមាចំនួន ១៦ ដូចជា[10] ៖១/សេចក្តីជូនដំណឹងចំពោះវិនិយោគិន, ២/គម្រោងរំពឹងទុកនៃការបោះផ្សាយ, ៣/អត្តសញ្ញាណនៃបុគ្គលពាក់ព័ន្ធនឹងការរៀបចំឯកសារផ្តល់ពត៌មាន, ៤/និយមន័យ អក្សរកាត់ និងពាក្យបច្ចេកទេស, ៥/សេចក្តីសង្ខេបឯកសារផ្តល់ពត៌មាន, ៦/ពត៌មានស្តីពីសំណោះបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ, ៧/ពត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ, ៨/ព័ត៌មានទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ, ៩/ព័ត៌មានស្តីពីប្រតិបត្តិការដោយរួមបញ្ចូលទាំងយុទ្ធសាស្ត្រ និងផែនការធុរកិច្ច ១០/ពត៌មានស្តីពីកត្តាហានិភ័យ, ១១/ពត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម, ១២/ពត៌មានស្តីពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ, ១៣/ព័ត៌មានហិរញ្ញវត្ថុ និង/ឬព័ត៌មានហិរញ្ញវត្ថុរួម, ១៤/ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ, ១៥/ពត៌មានផ្សេងៗ និង ១៦/ឧបសម្ព័ន្ធ។

[10] ប្រការ ១២ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ឯកសារផ្តល់ពត៌មានត្រូវមានសេចក្តីបញ្ជាក់ថា "*ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ពត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលដាក់ពាក្យស្នើសុំ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ*"។

ជាមួយគ្នានេះ ឯកសារផ្តល់ព័ត៌មានក៏ត្រូវបង្ហាញនូវព័ត៌មានសង្ខេបមួយចំនួនដូចជា៖ ទិដ្ឋភាពទូទៅរបស់បុគ្គលដាក់ពាក្យស្នើសុំ, ព័ត៌មានស្តីពីយុទ្ធសាស្ត្រ និងផែនការធុរកិច្ច, ព័ត៌មានស្តីពីអភិបាល និងភាគហ៊ុនិក, ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ, ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ និងព័ត៌មានស្តីពីកត្តាហានិភ័យផងដែរ។

### ខ. ការអនុញ្ញាត និងការបដិសេធឱ្យបោះផ្សាយ

អគ្គនាយក **គ.ម.ក.** ជាអ្នកត្រួតពិនិត្យនូវឯកសារផ្តល់ពត៌មាន និងជាអ្នកផ្តល់ការអនុញ្ញាត ឬបដិសេធឲ្យបោះផ្សាយមូលបត្របំណុលជាសាធារណៈ។ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំពីការអនុញ្ញាត ឬមិនអនុញ្ញាតជាគោលកា រណ៍លើការចុះបញ្ជីឯកសារផ្តល់ពត៌មានក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ[11]។

ក្នុងករណីដែលឯកសារនោះមិនបានធ្វើដោយត្រឹមត្រូវ មានការខ្វះចន្លោះ ឬកង្វះខាតនូវព័ត៌មានទាំងឡាយ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការបដិសេធមិនផ្តល់ការអនុញ្ញាតចុះបញ្ជីលើឯកសារផ្តល់ព័ត៌មាននោះបាន។ ប៉ុន្តែ ការបដិសេធគឺត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដូចការលើកឡើងខាងលើ ដោយផ្អែកលើមូលហេតុដូចជា[12] ៖

១. បុគ្គលដាក់ពាក្យស្នើសុំ មិនបំពេញលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២. ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈមិនពេញលេញ ក្លែងបន្លំ ឬនាំឱ្យយល់ខុស ឬមានរំលងព័ត៌មានសំខាន់ផ្សេងទៀត។

៣. បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤. ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥. បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ៖

[11] ប្រការ ២៦ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[12] ប្រការ ២៧ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ក. មិនមានលក្ខណៈសម្បត្តិ និងអត្តចរិតល្អ។

ខ. បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឲ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពចំពោះការសម្រេចចិត្តរបស់ខ្លួន។

គ. បានធ្វើអាជីវកម្មលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ. ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួនដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង. ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបានក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦. អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលបានធ្លាប់ប្រកាសក្ស័យធុន ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧. ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានានូវដំណើរការនៃដធុរកិច្ចប្រកបដោយចីរភាព និងទុកចិត្តបាន។

៨. នៅពេលកើតហេតុណាមួយដែលនាំឲ្យ ៖

ក. អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ. មិនមានភាពជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩. ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំនឹងនាំឲ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈដោយត្រូវពិចារណាលើលក្ខខណ្ឌនៃពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ។

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាគោលការណ៍លើឯកសារផ្តល់ព័ត៌មាន អាចទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ទាប់ពី ៖ ១/បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្របំណុល ដែលការកំណត់ថ្លៃលក់មូលបត្របំណុលនេះទទួលបានការបញ្ជាក់ពីទីផ្សារមូលបត្រប្រតិស្រុត និង ២/បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្របំណុលជាសាធារណៈពីអគ្គនាយកនៃ គ.ម.ក.។

### គ. កម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ពត៌មាន

ចំពោះកម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ពត៌មាន ត្រូវបានកំណត់ខុសៗគ្នាទៅតាមសណ្ឋានដូចខាងក្រោម ៖

- **ថ្លៃពាក្យសុំ និងសោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារពត៌មាន**[13] ៖ បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ត្រូវបង់ថ្លៃនៅពេលដាក់ពាក្យស្នើសុំឲ្យ **គ.ម.ក.** ដូចជា ៖
  - ករណីសំណើលក់មូលបត្របំណុលថ្មីជាសាធារណៈ ៖ ជាប្រាក់ចំនួន ១២,០០០,០០០ (ដប់ពីរលាន) រៀល
  - ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម ៖ ជាប្រាក់ចំនួន ៨,០០០,០០០ (ប្រាំបីលាន) រៀល ។
- **សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស**[14] ៖ បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួសនៅពេលដាក់ពាក្យស្នើសុំឲ្យ **គ.ម.ក** ដូចខាងក្រោម ៖
  - ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ ៖ ១/ជាប្រាក់ចំនួន ១,២០០,០០០ (មួយលានពីរសែន) រៀល
  - ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម ៖ ២/ប្រាក់ចំនួន ៨០០,០០០ (ប្រាំបីសែន) រៀល ។
- **សោហ៊ុយសិក្សាចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព**[15] ៖ បុគ្គលស្នើសុំចុះបញ្ជីឡើងវិញនូវឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ត្រូវចង់សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឡើងវិញឲ្យ **គ.ម.ក.** ដូចខាងក្រោម៖
  - ករណីសំណើបោះផ្សាយលក់មូលបត្របំណុលថ្មីជាសាធារណៈ ៖ ជាប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល
  - ករណីសំណើបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបន្ថែម៖ ជាប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល។

[13] ប្រការ ៤២ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[14] ប្រការ ៤៣ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[15] ប្រការ ៤៤ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារទាំងនេះ មិនត្រូវបានប្រគល់ឲ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាឯកសារផ្តល់ព័ត៌មានមិនបានទទួលការអនុញ្ញាត និងចុះបញ្ជីក៏ដោយ[16]។

### ឃ. ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសំណើបោះផ្សាយ និងការលក់មូលបត្របំណុលជាសាធារណៈត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.**។ មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន បុគ្គលបោះផ្សាយអាចធ្វើសកម្មភាព ទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិ-យោគទាំងនោះព្រមទាំងឯកសារពាក់ព័ន្ធ។ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន បុគ្គលបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដសូ និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយក **គ.ម.ក** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។ បុគ្គលបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឲ្យសាធារណជននៅបុគ្គលបោះផ្សាយ ក្រុមហ៊ុនមូលបត្រ និងប្រតិបត្តិករមូលបត្រ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**[17]។

មុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្មមូលបត្របំណុលចំនួនយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បុគ្គលបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ពី **គ.ម.ក** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម[18] ៖

១/ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀតរបស់បុគ្គលបោះផ្សាយ; ២/ចំនួន និងប្រភេទមូលបត្របំណុលដែលត្រូវធ្វើសំណើលក់; ៣/ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យសុំធ្វើបរិវិសកម្មមូលបត្របំណុល; ៤/កាលបរិច្ឆេទនៃការធ្វើបរិវិសកម្មមូលបត្របំណុល; ៥/សេចក្តីថ្លែងដើម្បីឲ្យសាធារណជនដឹងថាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជីពី **គ.ម.ក.**; ៦/សេចក្តីថ្លែង-ការណ៍ដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកលើឯកសារសំណើលក់

[16] ប្រការ ៤៥ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[17] ប្រការ ៣៧ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[18] ប្រការ ៣៨ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

មូលបត្របំណុល; ៧/សេចក្តីថ្លែងដើម្បីឲ្យសាធារណជនដឹងថា ការជូនដំណឹងនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះមិនមែនអញ្ជើញឲ្យធ្វើបរិវិសកម្មមូលបត្របំណុលឡើយ។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ បុគ្គលបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច។ ប៉ុន្តែបុគ្គលបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់អេឡិចត្រូនិច ឲ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលក្នុងទម្រង់បោះពុម្ព។

**ខ. ការដាក់លក់មូលបត្របំណុលជាសាធារណៈ**

បន្ទាប់ពីបានរៀបចំលក្ខខណ្ឌនៃសំណើលក់ និងទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្របំណុលជាសាធារណៈ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលទទួលការបញ្ជាក់ពីទីផ្សារមូលបត្រប្រតិស្រុត[19] ទើបបុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាគោលការណ៍លើឯកសារផ្តល់ពត៌មានអាចទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ពត៌មានពីអគ្គនាយក **គ.ម.ក.**។

**ខ.១. ការធ្វើបរិវិសកម្ម**

បន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាពសម្រាប់រយៈពេលមិនលើសពី ០៦ ខែ គិតចាប់ពីថ្ងៃដែលឯកសារផ្តល់ព័ត៌មានបានចុះបញ្ជី។ ក្រុមហ៊ុនបោះផ្សាយ ឬនីតិបុគ្គលប្រតិស្រុតអាចស្នើសុំពន្យារពេលការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈបានយ៉ាងតិច ៣០ ថ្ងៃ មុនផុតរយៈពេល ០៦ ខែនេះ[20]។ ទម្រង់ស្នើសុំធ្វើបរិវិសកម្មនឹងត្រូវកំណត់ដោយ**គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់នៅពេលដែលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែមានករណីដូចជា៖ ១/ ក្នុងរយៈពេលធ្វើបរិវិសកម្មមានឯកសារផ្តល់ព័ត៌មានបន្ថែម ដែលតម្រូវឱ្យមានការអនុញ្ញាត និងចុះបញ្ជីពាក់ព័ន្ធនឹងសំណើលក់មូលបត្រដែលតម្រូវឱ្យបុគ្គលដែលធ្វើសំណើលក់ជាសាធារណៈត្រូវជូនដំណឹងដល់អ្នកធ្វើបរិវិសកម្ម ចំពោះសំណើលក់មូលបត្រនោះថា អ្នកធ្វើបរិវិសកម្មអាចដកស្ទីការ ដែលបានធ្វើចំពោះសំណើលក់ជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ; ២/សំណើលក់ជាសាធារណៈនោះមិនទទួលបានជោគជ័យ; ៣/ការព្យួរឯកសារ

[19] ប្រការ ២៨ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[20] ចំណុចទី៣ មាត្រា ៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ផ្តល់ព័ត៌មានដែលចុះបញ្ជីរួច; ៤/មានការផ្សព្វផ្សាយជាសាធារណៈអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន; ៥/ការធ្វើបរិវិសកម្មមិនបានជោគជ័យ។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងករណីដោយឡែកនៅធនាគារពាណិជ្ជ។ បញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មមូលបត្របំណុលត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ[21]។

នៅពេលការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវបានបញ្ចប់ពេញលេញ បុគ្គលបោះផ្សាយត្រូវផ្តល់របាយ-ការណ៍ស្តីពីការធ្វើបរិវិសកម្មមូលបត្របំណុលនោះភ្លាមមក **គ.ម.ក.**។ ការរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្របំណុល គឺធ្វើតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក** ដោយភ្ជាប់មកជាមួយលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជអំពីចំនួនទឹកប្រាក់នៅក្នុងគណនីដាច់

ដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះនៅធានាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ[22]។ ករណីមូលបត្របំណុលធ្វើបរិវិសកម្មមិនអស់ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្មមូលបត្របំណុល ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់បុគ្គលបោះផ្សាយ ត្រូវធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទៅឲ្យបុគ្គលបោះផ្សាយក្នុងរយៈយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ បុគ្គលបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្របំណុលដែលសល់មក **គ.ម.ក.** ភ្លាម[23]។

ក្រុមហ៊ុនមូលបត្រ ត្រូវបែងចែកមូលបត្របំណុលក្នុងថ្លៃដែលបានកំណត់ក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជី។ បុគ្គលបោះផ្សាយ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបែងចែក និងបញ្ជូនមូលបត្របំណុលទៅឲ្យអ្នកដែលបានធ្វើបរិវិសកម្មដោយជោគជ័យក្នុងរយៈពេលយ៉ាងយូរ **១៥**(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីការបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្មមូលបត្របំណុល[24]។

### ខ.២. ការព្យួរ ឬលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ពត៌មាន

ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួច អាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ការទទួលពាក្យស្នើសុំធ្វើ បរិវិសកម្មមូលបត្របំណុល និងត្រូវជូនដំណឹងភ្លាមអំពីការព្យួរនេះទៅដល់អ្នកធ្វើបរិវិសកម្ម និងសាធារណៈ។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុន

[21] ប្រការ ២៩ វាក្យខណ្ឌទី ២ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[22] ប្រការ ៣៥ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[23] ប្រការ ៣០ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[24] ប្រការ ៣១ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

មូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មមូលបត្របំណុលថា មានសិទ្ធិអាចដកស៊ីការដែលបានធ្វើឡើងចំពោះសំណើលក់មូលបត្របំណុលជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ បុគ្គលបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលឡើងវិញបន្ទាប់ពីបញ្ហាដែលបានបណ្តាលឲ្យមានការព្យួរឯកសារផ្តល់ព័ត៌មានត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយក **គ.ម.ក.**[25]។

បុគ្គលបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននោះដល់អ្នកធ្វើបរិវិសកម្ម និងសាធារណៈជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយក **គ.ម.ក.** កាលណាមានករណីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយមានបញ្ជាក់ជាមួយមូលហេតុដូចជា[26]៖

១/ មូលហេតុដែលនាំឱ្យមានការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន; ២/កាលបរិច្ឆេទនៃការសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន; ៣/ពេលវេលា ទីកន្លែង និងរបៀបនៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ប្រាក់រួច ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម ការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រាប់លុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ៤/ ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ។

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរក្នុងករណីការធ្វើបរិវិសកម្មមូលបត្របំណុលមិនបានជោគជ័យ[27]។

### ៣. ដំណាក់កាលក្រោយបោះផ្សាយ

ក្រោយពេលបោះផ្សាយលក់មូលបត្របំណុល បុគ្គលបោះផ្សាយត្រូវអនុវត្តឲ្យពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម និងត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក.** ក្នុងករណីមានព្រឹត្តិការណ៍ដូចខាងក្រោម[28]៖

ក. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំកិច្ចប្រជុំម្ចាស់មូលបត្របំណុល ដោយលម្អិតអំពីទីកន្លែង ពេលវេលា របៀបវារៈប្រជុំ និងលក្ខខណ្ឌសម្រាប់ការចូលរួម និងអ្នកចូលរួម។

ខ. សេចក្តីសម្រេចរបស់ម្ចាស់មូលបត្របំណុលក្រោយកិច្ចប្រជុំ។

គ. នៅពេលមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន។

---

[25] ប្រការ ៣២ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[26] ប្រការ ៣៣ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[27] ប្រការ ៣៤ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

[28] ប្រការ ៣៩ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

ឃ. នៅពេលដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពបង់ការប្រាក់ និង/ឬប្រាក់ដើមទៅតាមរយៈពេលនៃការទូទាត់ដូចមានចែងក្នុងលក្ខខណ្ឌនៃមូលបត្របំណុល។

ឃ. នៅពេលមានការបង់ប្រាក់។

ង. នៅពេលមានគម្រោងធ្វើការពន្យាពេលបង់ការប្រាក់នៃមូលបត្របំណុល។

ច. នៅពេលដែលបុគ្គលបោះផ្សាយទិញមកវិញនូវមូលបត្របំណុលមួយផ្នែក ឬទាំងអស់របស់ខ្លួនពីទីផ្សារបន្ទាប់។

ឆ. រាយការណ៍ជូន **គ.ម.ក.** ជាប្រចាំឆ្នាំបន្ទាប់ពីទទួលបានរបាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** នូវការធ្វើចំណាត់ថ្នាក់លទ្ធភាព សងបំណុលរហូតដល់ការសងត្រឡប់ប្រាក់ដើមបញ្ចប់។ អគ្គនាយកនៃ **គ.ម.ក.** អាចលើកលែងនូវការ រាយការណ៍អំពីការធ្វើចំណាត់ថ្នាក់លទ្ធភាពសងបំណុល ដោយពិចារណាពីភាពចាំបាច់នៃព័ត៌មានអំពីការធ្វើចំណាត់លទ្ធភាពសងបំណុលចំពោះវិនិយោគិន។

៩. ករណីមានការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

១០. ករណីមានការផ្លាស់ប្តូរ ឬកែប្រែលក្ខខណ្ឌ និង/ឬទ្រព្យធានានៃមូលបត្របំណុលដោយត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំម្ចាស់មូលបត្របំណុលដោយត្រូវបញ្ជាក់ពីមូលហេតុនៃការផ្លាស់ប្តូរ ឬការកែប្រែ និងវិបាកដែលកើតមាន ឬអាចនឹងកើតមានចំពោះការសម្រេចចិត្តរបស់មូលបត្របំណុល។

១១. នៅពេលដែលគណនីរបស់បុគ្គលបោះផ្សាយនៅធនាគារត្រូវបានបង្កក ឬគណនីរបស់បុគ្គលបោះផ្សាយត្រូវបានអនុញ្ញាតឲ្យដំណើរការឡើងវិញបន្ទាប់ពីមានការបង្កកគណនីនោះ។

១២. នៅមានដែលមានព័ត៌មានដែលអាចមានឥទ្ធិពលដល់បុគ្គលបោះផ្សាយ និង/ឬមានឥទ្ធិពលលើទំនុកចិត្តឥណទាន (Credit Worthiness) របស់បុគ្គលបោះផ្សាយ។

ការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល តម្រូវឱ្យបុគ្គលបោះផ្សាយស្នើសុំការអនុញ្ញាតពីអគ្គ-នាយក **គ.ម.ក.** ជាមុន ។ បុគ្គលបោះផ្សាយត្រូវដាក់ជូន **គ.ម.ក.** នូវកិច្ចព្រមព្រៀងភ្នាក់ងរតំណាងម្ចាស់មូលបត្របំណុលថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីកាលបរិច្ឆេទតែងតាំង ក្រោយពីទទួលបានការអនុញ្ញាតពីអគ្គនាយក **គ.ម.ក.**[29]។

[29] ប្រការ ៤១ នៃប្រកាសស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ

## កថាខណ្ឌទី ៣ ៖ ការចុះបញ្ជីលក់មូលបត្របំណុលនៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

### ១. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល ដោយត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីលក់មូលបត្របំណុលនៅ **ផ.ម.ក.**។

បុគ្គលស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលត្រូវផ្តល់ព័ត៌មាន និងឯកសារភ្ជាប់ដូចជា ៖

ក. ពត៌មានទូទៅ(ឈ្មោះ; អាសយដ្ឋានទាំងជាភាសាខ្មែរ និងឡាតាំង; កាលបរិច្ឆេទនៃការបង្កើត; កម្មវត្ថុអាជីវ-កម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ)

ខ. លក្ខន្តិកៈរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

គ. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

ឃ. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

ង. លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

ច.លិខិតប្រគល់សិទ្ធិជូនបុគ្គលតំណាងឲ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល និងឯកសារបញ្ជាក់អត្ត-សញ្ញាណរបស់បុគ្គលតំណាង។

ឆ. ព័ត៌មានអំពីភាគហ៊ុនិក។

ជ. ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម។

ឈ. ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន ពត៌-មានអំពីធុរកិច្ច និងពត៌មានអំពីហានិភ័យ។

ញ. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលរួមមាន ៖

- ព័ត៌មានសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុ ដោយរាប់បញ្ចូលទាំងព័ត៌មានអំពីមូលបត្របំណុល និងមូលបត្រកម្មសិទ្ធទាំងអស់ និងលទ្ធភាពទទួលបានប្រាក់ចំណេញ។
- ការវាយតម្លៃទ្រព្យសកម្ម និង/ឬ ការវាយរម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម អនុលោមតាមលក្ខខណ្ឌតម្រូវនៃការប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ដ. របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា ( គ.ម.ក ) ឬរបាយការណ៍ស្តីពីអនុបាតចំនេញភាព និងលំហូរសាច់ប្រាក់ (Profitability and Cash Flow Ratio) អនុបាតឡេវើរែ៍ច (Leverage Ratio) និងអនុបាតលទ្ធភាពសង (Coverage Ratio) ជាដើម ដែលមានការបញ្ជាក់ពីភាពសមស្របដោយអ្នកជំនាញ ឬក្រុមហ៊ុនធានាទិញ

មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលជាសញ្ញាបត្រធម្មតា ករណីពុំទាន់មានភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ពី គ.ម.ក។

ឋ. ពត៌មានពាក់ព័ន្ធនឹងវត្ថុធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា។

ឌ. ពត៌មានពាក់ព័ន្ធនឹងបុគ្គលធានាដែលរួមមាន ព័ត៌មានទូទៅ របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា និងកិច្ចព្រមព្រៀងធានាជាមួយបុគ្គលធានា ករណីបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានាដែលទទួលបានការទទួលស្គាល់ពីគណកម្មការមូលបត្រកម្ពុជា (គ.ម.ក)។

ឍ. ឯកសារស្តីពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជីលក់ដែលមានព័ត៌មានដូចខាងក្រោម៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលឲ្យធ្វើការបោះផ្សាយមូលបត្របំណុល
- សេចក្តីលម្អិតពីមូលបត្របំណុលដែលស្នើសុំចុះបញ្ជី
- អត្រាគូប៉ុង និងកាលវិភាគទូទាត់ការប្រាក់
- តម្លៃចារឹកនៃមូលបត្របំណុល
- កាលបរិច្ឆេទបោះផ្សាយ និងឥណប្រតិទិន
- ផែនការបែងចែកមូលបត្របំណុល
- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្របំណុល។

ឃ. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុលចតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

ណ. ពត៌មានចាំបាច់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល។

ប្រសិនបើបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ឯកសារតម្រូវនៅក្នុងចំណុចទី១, ទី២, ទី៣, ទី៤, ទី៥, ទី៧, ទី៨ និងទី៩ ខាងលើ ត្រូវបានលើកលែង ប្រសិនបើពត៌មានទាំងនោះត្រូវបានធ្វើបច្ចុប្បន្នកម្មមក **ផ.ម.ក** រួចហើយ។

**ផ.ម.ក** ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។ រយៈពេលនៃការត្រួតពិនិត្យត្រូវបានកាត់បន្ថយមកត្រឹមយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការប្រសិនបើបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

ករណី **ផ.ម.ក** បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ផ.ម.ក ត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ

ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលអាចស្នើសុំការបំភ្លឺពី ផ.ម.ក ។ បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

**២. លក្ខខណ្ឌ និងនីតិវិធីដែលចុះបញ្ជីលក់មូលបត្រ**

ក្នុងរយៈពេល **៧** (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្របំណុលត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុល ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ **ផ.ម.ក** ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើងលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **ក.ម.ក** ៖

ក. មូលធនភាគហ៊ុនិកសរុប ត្រូវមានយ៉ាងតិចចំនួន **២.000.000.000** (ពីរពាន់លាន) រៀល លើកលែងចំពោះការចុះបញ្ជីសញ្ញាបណ្ណមានវត្ថុធានា។

ខ. ទំហំមូលបត្របំណុលដែលបោះផ្សាយ និងចុះបញ្ជី ត្រូវមានយ៉ាងតិចចំនួន **១.000.000.000** (មួយពាន់លាន) រៀល ឬយ៉ាងតិចចំនួន **៥00.000.000** (ប្រាំរយលាន) រៀល ចំពោះសញ្ញាបណ្ណមានវត្ថុធានា។

គ. តម្លៃចារឹក ត្រូវមានតម្លៃ **១00.000** (មួយរយពាន់) រៀល។

ឃ. មូលបត្របំណុលទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅនឹងប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក។

ក្នុងការបំពេញនីតិវិធីនៃការចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលត្រូវផ្តល់ជូន ផ.ម.ក នូវឯកសារភ្ជាប់ខាងក្រោម៖

ក. ឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាស្ថាពររួចនៅ ផ.ម.ក។

ខ. ឯកសារបញ្ជាក់ពីការទូទាត់បរិវិសកម្មមូលបត្របំណុល។

គ. លិខិតបញ្ជាក់អំពីការដាក់ពាក្យផ្ញើមូលបត្របំណុលនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក។

ឃ. របាយការណ៍បែងចែកមូលបត្របំណុល។

ង. ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងដែលធ្វើឡើងជាមួយនឹងភ្នាក់ងារតំណាងអ្នកកាន់កាប់មូលបត្របំណុល ឬបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់។

ច. ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ។

មុននឹងត្រូវបានចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការនៅ **ផ.ម.ក** បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលត្រូវចុះកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្របំណុលជាមួយ **ផ.ម.ក** ហើយកិច្ចព្រមព្រៀងនេះនឹងមានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ។ បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញរួច **ផ.ម.ក** ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលក្នុងរយៈពេល **៥** (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ។

ស្របទៅតាមលក្ខខណ្ឌ និងនិតិវិធីដែលបានរៀបរាប់ខាងលើ ក្នុងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនក៏បានចែងនូវទោសបញ្ញត្តិដើម្បីទប់ស្កាត់ការបោះផ្សាយ និងជួញដូរមូលបត្របំណុលដែលមិនប្រព្រឹត្តទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

បុគ្គលណាដែលបោះផ្សាយ និងលក់មូលបត្រជាសាធាណៈដោយគ្មានការអនុញ្ញាតពី **គ.ម.ក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១** (មួយ) ឆ្នាំ ដល់ **៥** (ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី **២.០០០.០០០** (ពីរលាន) រៀល ដល់ **១០.០០០.០០០** (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានដូចចំណុចខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី **២០.០០០.០០០** (ម្ភៃលាន) រៀល ដល់ **៥០០.០០០.០០០** (ប្រាំរយលាន) រៀល[30]។

បុគ្គលណាដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១** (មួយ) ឆ្នាំ ដល់ **៥** (ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី **២.០០០.០០០** (ពីរលាន) រៀល ដល់ **១០.០០០.០០០** (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងដូចចំណុចខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី **២០.០០០.០០០** (ម្ភៃលាន) រៀល ដល់ **៥០០.០០០.០០០** (ប្រាំរយលាន) រៀល[31]។

បុគ្គល ឬក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមិនបានបំពេញកាតព្វកិច្ចតាមកថាខណ្ឌទី ១នៃមាត្រា ២០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនឬដែលផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈដោយគ្មានការអនុញ្ញាតពី និងចុះបញ្ជីនៅ **គ.ម.ក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១** (មួយ) ឆ្នាំ ដល់ **៥** (ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី **២.០០០.០០០** (ពីរលាន) រៀល ដល់ **១០.០០០.០០០** (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងដូចចំណុចខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី **២០.០០០.០០០** (ម្ភៃលាន) រៀល ដល់ **៥០០.០០០.០០០** (ប្រាំរយលាន) រៀល[32]។

[30] មាត្រា ៤៧ នៃច្បាប់ស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

[31] មាត្រា ៤៨ នៃច្បាប់ស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

[32] មាត្រា ៤៩ នៃច្បាប់ស្តីពី ការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

### ៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

- **ថ្លៃសេវាសម្រាប់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល[33] ៖** បុគ្គលស្នើសុំចុះបញ្ជីលក់មូល
  បត្របំណុលត្រូវបង់ថ្លៃសេវា **ផ.ម.ក** លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលចំនួន **៤.០០០.០០០** (បួនលាន)រៀល នៅពេលដាក់ពាក្យស្នើសុំ។
- **ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្របំណុល[34] ៖** បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា **ផ.ម.ក** សម្រាប់ការចុះបញ្ជីមូលបត្របំណុលដោយផ្អែកលើទំហំមូលបត្របំណុលដែលចុះបញ្ជីដែលត្រូវគណនា ប្រដេញជាដំណាក់កាលតាមតារាងដូចខាងក្រោម ៖

| ទំហំមូលបត្របំណុលដែលចុះបញ្ជីសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ២០.០០០.០០០០.០០០ ៛ | ៣.០០០.០០០ ៛ |
| ពី | ២០.០០០.០០០០.០០១ ៛ | ដល់ | ៤០.០០០.០០០០.០០០ ៛ | ០,០២៥% |
| ពី | ៤០.០០០.០០០០.០០១ ៛ | ដល់ | ៨០.០០០.០០០០.០០០ ៛ | ០,០១៥% |
| ពី | ៨០.០០០.០០០០.០០១ ៛ | ដល់ | ១២០.០០០.០០០០.០០០ ៛ | ០,០១០% |
| | | លើសពី | ១២០.០០០.០០០០.០០០ ៛ | ០,០០៥% |

ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលសរុបមិនត្រូវលើសពី ២០.០០០.០០០០.០០០ (ម្ភៃលាន) រៀលឡើយ និងត្រូវបង់មុនថ្ងៃចុះបញ្ជីជាផ្លូវការ។

- **ថ្លៃសេវាសម្រាប់ចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំ[35] ៖** បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំ ដោយផ្អែកលើទំហំមូលបត្របំណុលដែលចុះបញ្ជី ដែលត្រូវគណនាប្រដេញជាដំណាក់កាលតាមតារាងដូចខាងក្រោម ៖

| ទំហំមូលបត្របំណុលដែលចុះបញ្ជីសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ២០.០០០.០០០០.០០០ ៛ | ១.០០០.០០០ ៛ |
| ពី | ២០.០០០.០០០០.០០១ ៛ | ដល់ | ៤០.០០០.០០០០.០០០ ៛ | ០,០២៥% |

[33] ប្រការ ១៨ ថ្មី - ឧបសម្ព័ន្ធប្រកាសលេខ ០០៣,₂₀ / ប្រ.ក ស្តីពីការកែប្រែវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

[34] ប្រការ ១៩ ថ្មី - ឧបសម្ព័ន្ធប្រកាសលេខ ០០៣,₂₀ / ប្រ.ក ស្តីពីការកែប្រែវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

[35] ប្រការ ២០ ថ្មី - ឧបសម្ព័ន្ធប្រកាសលេខ ០០៣,₂₀ / ប្រ.ក ស្តីពីការកែប្រែវិធានចុះបញ្ជីលក់មូលបត្របំណុលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

| | | | | |
|---|---|---|---|---|
| ពី | ៤០.០០០.០០០០.០០១ រ | ដល់ | ៨០.០០០.០០០០.០០០ រ | ០,០១៥% |
| ពី | ៨០.០០០.០០០០.០០១ រ | ដល់ | ១២០.០០០.០០០០.០០០ រ | ០,០១០% |
| | | លើសពី | ១២០.០០០.០០០០.០០០ រ | ០,០០៥% |

ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំសរុបមិនត្រូវលើសពី ១០.០០០.០០០០.០០០ (ដប់លាន) រៀល និងត្រូវបង់យ៉ាងយូររយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយពេលចុះបញ្ជីលក់មូលបត្របំណុល ជាផ្លូវការ និងសម្រាប់ឆ្នាំបន្តបន្ទាប់ ត្រូវបង់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែមករា ជារៀងរាល់ឆ្នាំ។

## ផ្នែកទី ២ ៖ នីតិវិធីនៃការបោះផ្សាយលក់មូលបត្របំណុលនៅថៃ

ចំពោះមូលបត្របំណុលសាជីវកម្ម ការបោះផ្សាយត្រូវស្ថិតនៅក្រោមការយល់ព្រមរបស់គណកម្មការមូលបត្រ។ ការបោះផ្សាយមូលបត្រសាជីវកម្មនៅប្រទេសថៃ បែងចែកជា ២ ផងដែរគឺ ៖ ការបោះផ្សាយដោយសាធារណៈ (Public Offering) និងការបោះផ្សាយដោយឯកជន (Private Offering)។

ដោយបរិបទនៃប្រទេសកម្ពុជា យើងលើកមកបង្ហាញចំពោះតែការបោះផ្សាយដោយសាធារណៈ ដូច្នេះប្រធានបទនៃប្រទេសថៃយើងក៏បានលើកយកតែការបោះផ្សាយដោយសាធារណៈមកបង្ហាញប៉ុណ្ណោះ។

### កថាខណ្ឌទី ១ ៖ សំណើលក់មូលបត្របំណុល

គ្មានក្រុមហ៊ុនណាដែលអាចធ្វើសំណើលក់មូលបត្រដែលថ្មីក្នុងប្រភេទជាភាគហ៊ុន; មូលបត្របំណុល, វិញ្ញាបនបត្រដែលតំណាងឱ្យសិទ្ធិក្នុងការទិញភាគហ៊ុន, វិញ្ញាបនបត្រតំណាងឱ្យសិទ្ធិក្នុងការទិញមូលបត្របំណុល និងមូលបត្រផ្សេងទៀតដូចដែលបានបញ្ជាក់ពីគណកម្មការមូលបត្រ លើកលែងតែសំណើនោះ[36] ៖

១. ជាការបោះផ្សាយបណ្ណរតនាគារ, សញ្ញាបណ្ណរដ្ឋ, សញ្ញាបណ្ណដែលដើមទុន និងអត្រាការប្រាក់ត្រូវកំណត់ដោយក្រសួងហិរញ្ញវត្ថុ។

២. បានទទួលការយល់ព្រមពីការិយាល័យគណកម្មការមូលបត្រតាមរយៈការដាក់សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី (Registration Statement) និងសេចក្តីព្រាងពីការជូនពត៌មាន (Draft Prospectus) ឬ

៣. ជាសំណើលក់មូលបត្រថ្មីដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ហើយត្រូវបានធ្វើឡើងចំពោះម្ចាស់ភាគហ៊ុនទាំងស្រុងរបស់ខ្លួនក្នុងសមាមាត្រនៃភាគហ៊ុនដែលមានស្រាប់ និងក្នុងការពិចារណានៃការទូទាត់ពេញលេញសម្រាប់តម្លៃដែលបានស្នើ។

[36] Section 33.[4] of Securities and Exchange Act B.E. 2535 (As Amended)

## កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបោះផ្សាយមូលបត្របំណុល

### ១. ដំណាក់កាលនៃការដាក់ពាក្យ

#### ក. លក្ខណៈនៃអ្នកដាក់ពាក្យសុំ

ក្នុងករណីសំណើលក់សញ្ញាបណ្ណជាសាធារណៈ អ្នកដាក់ពាក្យត្រូវចាត់តាំងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល[37] ។ អ្នកស្នើសុំការបោះផ្សាយលក់សញ្ញាបណ្ណត្រូវគោរពតាមលក្ខណៈដូចខាងក្រោម[38] ៖

- របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់អ្នកដាក់ពាក្យសុំនៃឆ្នាំចុងក្រោយបំផុត និងរបាយ-ការណ៍ហិរញ្ញវត្ថុនៃត្រីមាសចុងក្រោយមុនពេលដាក់ពាក្យសុំត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ
  - ➢ របាយការណ៍ហិរញ្ញវត្ថុ ត្រូវរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រោមសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ
  - ➢ របាយការណ៍របស់សវនករមិនត្រូវមានចំណុចដូចខាងក្រោម៖
    - មតិយោបល់បដិសេធលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកដាក់ពាក្យសុំ និងរបាយការណ៍ហិរញ្ញវត្ថុរួម ឬគំនិតអវិជ្ជមាន។
    - យោបល់ដែលមានលក្ខណៈគ្រប់គ្រាន់លើប្រតិបត្តិការសំខាន់ៗណាមួយដែលមិនអនុលោម
      តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ។
    - ការសម្តែងមតិដែលថាវិសាលភាពសវនកម្មរបស់សវនករត្រូវបានកំណត់ដោយអំពើ ឬការលុបចោលសកម្មភាពណាមួយដោយអ្នកស្នើសុំ ដោយនាយកប្រតិបត្តិ ឬអភិបាលរបស់ខ្លួន។
- អ្នកដាក់ពាក្យសុំមិនស្ថិតក្នុងស្ថានភាពដូចខាងក្រោមនេះទេ លើកលែងតែមានការលើកលែងត្រូវបានផ្តល់ដោយការិយាល័យគណកម្មការមូលបត្រ៖

អ្នកដាក់ពាក្យសុំមិនបានបំពេញរបាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍ពាក់ព័ន្ធ ដែលជាករណីដូចជា;

---

[37] Clause 19 of Notification of the Capital Market Supervisory Board No. Tor Jor. 17/2561 Re: Application and Approval for Offer for Sale of Newly Issued Debt Securities

[38] Clause 16 of Notification of the Capital Market Supervisory Board No. Tor Jor. 17/2561 Re: Application and Approval for Offer for Sale of Newly Issued Debt Securities

  - ➢ អ្នកដាក់ពាក្យសុំមិនបានបំពេញរបាយការណ៍ដែលទាមទារដោយការិយាល័យគណកម្មការមូលបត្រ ឬផ្សារមូលបត្រ;
  - ➢ អ្នកដាក់ពាក្យសុំមិនត្រូវស្ថិតក្នុងដំណើរការកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឡើយ ឬរបាយការណ៍ដែលតម្រូវឱ្យរៀបចំឡើង តាមបញ្ជារបស់ការិយាល័យគណកម្មការមូលបត្រ ឬផ្សារមូលបត្រ;
  - ➢ អ្នកដាក់ពាក្យសុំមិនមានកាតព្វកិច្ចអាចបន្តអនុវត្តតាមបញ្ជាពីការិយាល័យគណកម្មការមូលបត្រ ឬផ្សារមូលបត្រ;

- អគ្គនាយក និងអភិបាលត្រូវបានចុះក្នុងបញ្ជីទិន្នន័យមូលដ្ឋាននៃអគ្គនាយក និងអភិបាលនៃក្រុមហ៊ុនបោះផ្សាយមូលបត្រក្រោមសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ
- អ្នកដឹកនាំរបស់អ្នកដាក់ពាក្យសុំមិនត្រូវមានលក្ខណៈមិនគួរឱ្យទុកចិត្តណាមួយតាមសេចក្តីជូនដំណឹងរបស់គណកម្មការមូលបត្រ
- អ្នកដាក់ពាក្យសុំមិនត្រូវមានចរិតលក្ខណៈដូចក្នុងចំណុចបន្ទាប់; លើកលែងតែករណីដែលអ្នកដាក់ពាក្យសុំជាក្រុមហ៊ុនចុះបញ្ជី ដែលមិនត្រូវមានកំណត់ត្រាធ្លាប់ល្មើសនឹងបទបញ្ជា ឬលក្ខខណ្ឌពាក់ព័ន្ធនឹងសំណើមូលបត្រនៅក្នុងចំណុចសំខាន់ៗ;
- មិនមានមូលហេតុដែលសង្ស័យថាឯកសារផ្តល់ព័ត៌មានបានបង្ហាញដល់សាធារណជនទូទៅមិនលក្ខណៈពេញលេញ ឬមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការវិនិយោគ ឬមានការភាន់ច្រឡំ;
- មិនមានមូលហេតុដែលសង្ស័យថាអគ្គនាយក និងម្ចាស់ភាគហ៊ុនធំៗ មានចរិតលក្ខណៈដូចខាងក្រោមៈ
  - មានផលប្រយោជន៍ផ្សេងទៀតដែលអាចប៉ះពាល់ដល់ផលប្រយោជន៍ចម្បងរបស់ជំនួញលើកលែងតែអ្នកដាក់ពាក្យសុំអាចបង្ហាញថាខ្លួនបានដាក់នូវយន្តការដែលធានាថាការគ្រប់គ្រងក្រុមហ៊ុននឹងទទួលបានផលប្រយោជន៍ខ្ពស់រួមទាំងសម្រាប់ម្ចាស់ភាគហ៊ុនទាំងមូល។
  - ទទួលបានការផ្ទេរអត្ថប្រយោជន៍ពីជំនួញ។
  - អ្នកដាក់ពាក្យសុំមិនបានខកខានការបង់ប្រាក់ដើម ឬបង់អត្រាការប្រាក់នៃមូលបត្របំណុល ឬការសងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជកម្ម ឬក្រុមហ៊ុនហិរញ្ញវត្ថុ ឬក្រុមហ៊ុនផ្តល់ប្រាក់កម្ចី ឬស្ថាប័នហិរញ្ញវត្ថុដែលបានបង្កើតឡើងក្រោមច្បាប់ជាក់លាក់។
- អ្នកដាក់ពាក្យសុំមិនបានរំលោភលក្ខខណ្ឌណាមួយដោយអនុលោមតាមលក្ខខណ្ឌ ។

អ្នកដាក់ពាក្យមិនត្រូវមានចរិកលក្ខណៈដូចខាងក្រោម លើកលែងតែអ្នកដាក់ពាក្យសុំបានកែតម្រូវមូលហេតុប្រព័ន្ធការងារ ការគ្រប់គ្រងរចនាសម្ព័ន្ធ និងការគ្រប់គ្រងប្រតិបត្តិការដែលបណ្តាលឱ្យអ្នកដាក់ពាក្យសុំមានចរិតលក្ខណៈដូចចំណុចខាងក្រោម៖

១. ក្នុងរយៈពេលប្រាំឆ្នាំ មុនកាលបរិច្ឆេទដាក់ឯកសារពាក្យសុំសម្រាប់ការបោះផ្សាយលក់មូលបត្របំណុលអ្នកដាក់ពាក្យសុំមិនត្រូវមានចរិកលក្ខណៈដូចខាងក្រោម[39] ៖

- មានកំណត់ត្រាធ្លាប់ល្មើសនឹងបទបញ្ជា ឬលក្ខខណ្ឌពាក់ព័ន្ធនឹងសំណើមូលបត្រនៅក្នុងចំណុចសំខាន់ៗ។
- ត្រូវបានបដិសេធដោយការិយាល័យគណកម្មការមូលបត្រទាក់ទងនឹងពាក្យសុំសម្រាប់ការបោះផ្សាយលក់មូលបត្រថ្មីដោយសារតែគួរឱ្យសង្ស័យទាក់ទងនឹងយន្តការនៃការគ្រប់គ្រងក្នុងលក្ខណៈណាមួយដូចខាងក្រោមៈ

  ក. មិនបានផ្តល់ឲ្យម្ចាស់ភាគហ៊ុនដោយស្មើភាពគ្នា ដោយបានផ្តល់ផលប្រយោជន៍ដល់ក្រុមណាមួយនៃម្ចាស់ភាគហ៊ុន ដែលបានបង្កើតជាគុណប្រយោជន៍លើម្ចាស់ភាគហ៊ុនផ្សេងទៀត ឬផ្តល់អត្ថប្រយោជន៍មិនសមរម្យជាងម្ចាស់ភាគហ៊ុនដទៃទៀត។

  ខ. មិនមានឆន្ទៈដើម្បីការពារសិទ្ធិរបស់ម្ចាស់ភាគហ៊ុន ដោយអនុញ្ញាតឱ្យមនុស្សម្នាក់ទទួលបានប្រាក់ចំណេញលើសពីអ្វីដែលគួរទទួលជាធម្មតា ឬដោយធ្វើឱ្យក្រុមហ៊ុនបាត់បង់ផល-ប្រយោជន៍ដែលគួរតែត្រូវបានទទួល។

  គ. ធ្លាប់មានពាក្យសុំស្នើសុំការបោះផ្សាយលក់មូលបត្របំណុលថ្មីដែលត្រូវបានច្រានចោលដោយការិយាល័យគណកម្មការមូលបត្រលើមូលដ្ឋានគួរឱ្យសង្ស័យដែលទាក់ទងទៅនឹងការបង្ហាញព័ត៌មានចំពោះសាធារណជន ឬការិយាល័យគណកម្មការមូលបត្រដែលមិនពេញលេញផ្ទុយពីការពិត មិនគ្រប់គ្រាន់ធ្វើការសម្រេចចិត្តវិនិយោគ ឬបំភាន់វិនិ-យោគិនក្នុងលក្ខណៈលាក់បាំង ឬបន្លំ ឬបង្កើតអង្គហេតុដែលមិនមាននៅក្នុងប្រតិបត្តិការ ឬប្រតិបត្តិការវិនិយោគសំខាន់ៗណាមួយ ។

  ឃ. បានដកពាក្យសុំសម្រាប់ការសម្រាប់ការបោះផ្សាយលក់ភាគហ៊ុនថ្មីដោយមិនមានការបញ្ជាក់ពីមូលហេតុដែលគួរអោយសង្ស័យតាម (ខ) ឬ (គ)ទៅកាន់ការិយាល័យគណកម្មការមូលបត្រ ឬដោយមានការបំភ្លឺដែលមិនមានអង្គហេតុ ឬសមហេតុផលដែលជាមូលដ្ឋានសម្រាប់ការពិចារណាឡើងវិញនៃការសង្ស័យនៅតាម(ខ) ឬ (គ)

[39] Clause 17 of Notification of the Capital Market Supervisory Board No. Tor Jor. 17/2561 Re: Application and Approval for Offer for Sale of Newly Issued Debt Securities

២. ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ មុនកាលបរិច្ឆេទដាក់ពាក្យសុំចំពោះសំណើលក់មូលបត្របំណុលថ្មី អ្នកដាក់ពាក្យសុំត្រូវបានដាក់ទោសសាលដីកាចុងក្រោយក្នុងបទល្មើសទាក់ទងនឹងទ្រព្យសម្បត្តិ សម្រាប់តែមូលហេតុដែលកើតឡើងពីការបោកប្រាស់ ការក្លែងបន្លំ ឬទង្វើមិនស្មោះត្រង់ដែលបណ្តាលឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរទាំងនៅក្រោមប្រទេសថៃ ឬច្បាប់បរទេស;

៣. បច្ចុប្បន្នកំពុងទទួលរងនូវបណ្តឹងព្រហ្មទណ្ឌ ឬការកាត់ទោសតាមផ្លូវច្បាប់ចំពោះបទល្មើសទាក់ទងនឹងទ្រព្យសម្បត្តិដោយភ្នាក់ងារដែលពាក់ព័ន្ធ សម្រាប់តែបុព្វហេតុដែលកើតឡើងពីអំពើបោកបញ្ឆោត ឆបោក ឬទង្វើមិនស្មោះត្រង់ដែលនាំឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរទាំងនៅក្រោមច្បាប់ថៃ ឬបរទេស;

៤. ជាបុគ្គលដែលស្ថិតនៅក្រោមការសង្ស័យដែលបានរៀបចំឲ្យក្លាយបុគ្គលដែលមានចរិតលក្ខណៈស្របតាម (១) (២) ឬ (៣) ដើម្បីចៀសវាងការអនុលោមតាមបទប្បញ្ញត្តិសម្រាប់ការពិចារណាតាម (១) (២) ឬ (៣) កំណត់ដោយការិយាល័យគណកម្មការមូលបត្រ។

### ខ. លក្ខខណ្ឌ និងនីតិវិធីក្នុងការដាក់ពាក្យសុំបោះផ្សាយ

ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រថ្មី និងការយល់អនុញ្ញាត ត្រូវគោរពតាមវិធានលក្ខខណ្ឌ និងនីតិវិធីដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ។ ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារអាចបញ្ជាក់លម្អិតអំពីបញ្ហាដូចខាងក្រោម[40] ៖

១. អនុបាតនៃបំណុលនឹងកម្មសិទ្ធិ

២. រយៈពេលសម្រាប់ការលក់មូលបត្រ។

៣. ការធ្វើបរិវិសកម្ម; ការធានាទិញមូលបត្រ និងការចែកចាយមូលបត្រ

៤. ការទទួលយកការទូទាត់ និងការប្រគល់មូលបត្រ

៥. ការការពារ និងការរៀបចំទាក់ទងនឹងការបង់ប្រាក់សម្រាប់ការធ្វើបរិវិសកម្មមូលបត្រ

៦. លក្ខខណ្ឌផ្សេងទៀតដែលចាំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈ។

ក្នុងការពិចារណាលើពាក្យសុំការអនុញ្ញាត; ការិយាល័យគណកម្មការមូលបត្រត្រូវជូនដំណឹងនៃលទ្ធផលទៅអ្នកដាក់ពាក្យក្នុងរយៈពេល **៤៥** (សែសិបប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំរួមជាមួយឯកសារដែលត្រឹមត្រូវ និងពេញលេញ។

ពាក្យសុំសម្រាប់ការអនុម័ត និងបំពេញពត៌មានអាចត្រូវបានធ្វើឡើងនៅការិយាល័យគណកម្ម-ការមូលបត្រក្នុងពេលតែមួយ ប៉ុន្តែសេចក្តីថ្លែងការណ៍ស្តីពីការចុះឈ្មោះ និងសេចក្តីព្រាងនឹងមានប្រសិទ្ធភាពលុះត្រាតែមានការយល់ព្រមពីការិយាល័យគណកម្មការមូលបត្រ។

---

[40] Section 36 Securities and Exchange Act B.E. 2535 (As Amended)

### ២. ការដាក់សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងនៃការជូនពត៌មាន

សំណើលក់មូលបត្រជាសាធារណៈ ឬទៅបុគ្គលណាម្នាក់ អាចត្រូវបានធ្វើឡើងនៅពេលដែលសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងពីការជូនពត៌មានដែលត្រូវបានដាក់ជូនការិយាល័យគណកម្មការមូលបត្រដោយអ្នកស្នើសុំរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬម្ចាស់មូលបត្របានក្លាយជាមានប្រសិទ្ធិភាព[41]។ ក្នុងករណីដែលសំណើលក់មូលបត្រជាសាធារណៈ ឬទៅបុគ្គលណាមួយដោយស្របតាមចំណុចខាងលើ តម្រូវឲ្យមានការអនុញ្ញាតពីការិយាល័យគណកម្មការមូលបត្រ នោះអ្នកស្នើសុំដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬក្រុមហ៊ុនអាចដាក់សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានរួមជាមួយគ្នាជាមួយនឹងពាក្យសុំការអនុញ្ញាត ឬអាចដាក់សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានបន្ទាប់ពីទទួលបានការអនុញ្ញាត[42]។

សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាននឹងក្លាយជាមានប្រសិទ្ធប្រសិនបើហួសរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីបានដាក់ជូនការិយាល័យគណកម្មការមូលបត្រ លើកលែងតែក្រុមប្រឹក្សាភិបាលត្រួតពិនិត្យទីផ្សារបានបញ្ជាក់កាលបរិច្ឆេទក្លាយមានប្រសិទ្ធិភាពមុនពេលដែលបានកំណត់នេះ[43]។

ក្នុងការបំពេញសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី ការិយាល័យគណកម្មការមូលបត្រអាចណែនាំអ្នកដាក់ពាក្យសុំ ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬម្ចាស់មូលបត្រដើម្បីភ្ជាប់ឯកសារណាមួយក្រៅពីឯកសារដែលបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី ។ ព័ត៌មានបន្ថែមដែលត្រូវផ្តល់ជូនតាមការរៀបរាប់ខាងលើមានដូចជា[44] ៖

ក. សិទ្ធិ និងការរឹតត្បិតទាក់ទងនឹងការផ្ទេរមូលបត្របំណុល

ខ. ការផ្ទេរត្រឡប់នៃមូលបត្របំណុល;

គ. ទ្រព្យសម្បត្តិ ឬវត្ថុធានាផ្សេងទៀត ដែលត្រូវបានប្រើសម្រាប់ការធានាសងត្រឡប់ (ប្រសិនបើមាន)

ឃ. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល (ប្រសិនបើមាន)

ង. ការជាប់ទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងករណីគ្មានការធានា;

ច. បំណុលដែលមិនទាន់សងពីមូលបត្របំណុលមុនៗ។

ឆ. នីតិវិធី ពេលវេលា និងទីកន្លែងនៃការសងប្រាក់;

---

[41] Section 65 Securities and Exchange Act B.E. 2535 (As Amended)

[42] Section 66 Securities and Exchange Act B.E. 2535 (As Amended)

[43] Section 67 Securities and Exchange Act B.E. 2535 (As Amended)

[44] Section 70 Securities and Exchange Act B.E. 2535 (As Amended)

ជ. នីតិវិធីសម្រាប់ការបំលែងសិទ្ធិ (ប្រសិនមាន)

ឈ.ព័ត៌មានផ្សេងៗទៀតដែលមានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ។

**ក. ទម្រង់នៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី**

សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី ត្រូវមានទម្រង់ដូចមានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់ក្រុម-ប្រឹក្សាត្រួតពិនិត្យទីផ្សារ ហើយត្រូវមានពត៌មានលម្អិតដូចខាងក្រោម[45] ៖

១. គោលបំណងនៃសំណើលក់មូលបត្រជាសាធារណៈ

២. ឈ្មោះក្រុមហ៊ុនបោះផ្សាយមូលបត្រ

៣. ដើមទុនរបស់ក្រុមហ៊ុន;

៤. ចំនួន និងប្រភេទនៃមូលបត្រដែលស្នើសុំធ្វើការលក់។

៥. តម្លៃលក់ក្នុងមួយឯកតានៃមូលបត្រ។

៦. ប្រភេទលក្ខណៈនៃអាជីវកម្ម;

៧. ស្ថានភាពហិរញ្ញវត្ថុ; ប្រតិបត្តិការអាជីវកម្ម និងព័ត៌មានសំខាន់ៗរបស់អាជីវកម្ម

៨. ការគ្រប់គ្រង និងម្ចាស់ភាគហ៊ុនសំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ

៩. សវនករ, ស្ថាប័នហិរញ្ញវត្ថុបានទាក់ទងជាទៀងទាត់ និងទីប្រឹក្សាច្បាប់នៃក្រុមហ៊ុនបោះផ្សាយមូលបត្រ

១០. នីតិវិធីសម្រាប់ការធ្វើបរិវិសកម្ម; ការធានាទិញ និងការបែងចែកមូលបត្រ។

១១. ព័ត៌មានផ្សេងៗទៀតដែលមានបញ្ជាក់ក្នុងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ ។

**ខ. ការដាក់ ឬកែប្រែនូវព័ត៌មានបន្ថែម**

ក្នុងករណីដែលការិយាល័យគណកម្មការមូលបត្រមានយោបល់ថា សេចក្តីថ្លែងការណ៍ ឬចំណុចណាមួយក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាន មិនមានភាពពេញលេញ នោះការិយាល័យគណកម្មការមូលបត្រមានសិទ្ធិបញ្ជាឲ្យបុគ្គលដាក់ពាក្យដាក់បន្ថែមនូវព័ត៌មានបន្ថែម ឬកែប្រែសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានតែម្តង។ ទោះជាយ៉ាងណា ការិយាល័យគណកម្មការមូលបត្រមិនអាចចេញបញ្ជាបែបនេះទេ បន្ទាប់ពីសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជីសេចក្តីព្រាងការជូនព័ត៌មានបានក្លាយជាមានប្រសិទ្ធភាព[46]។

មុនពេលកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬម្ចាស់មូលបត្រដែលមានបំណងចង់កែប្រែចំណុចណា

[45] Section 69 Securities and Exchange Act B.E. 2535 (As Amended)

[46] Section 73 Securities and Exchange Act B.E. 2535 (As Amended)

មួយ ឬពត៌មាននៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានអាចដាក់ជូនពាក្យសុំធ្វើការកែប្រែនេះទៅការិយាល័យគណកម្មការមូលបត្រ។ នៅពេលកែប្រែទាក់ទងនឹងព័ត៌មានសំខាន់ៗ, ការិយាល័យគណកម្មការមូលបត្រអាចចាត់ទុកថាកាលបរិច្ឆេទនៃការទទួលការធ្វើការកែប្រែនេះជាកាលបរិច្ឆេទចាប់ផ្តើមនៃរយៈពេលសម្រាប់ការដាក់ឯកសារថ្មីនៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាន[47]។

### ៣. ដំណាក់កាលនៃការបោះផ្សាយ

#### ក. ការបដិសេធមិនឱ្យបោះផ្សាយ

ក្នុងករណីដែលបង្ហាញឲ្យឃើញនូវអង្គហេតុឱ្យមានការសង្ស័យដូចខាងក្រោម ការិយាល័យគណកម្មការមូលបត្រមិនអាចផ្តល់ការយល់ព្រមសម្រាប់ការផ្តល់ជូនក្នុងការលក់មូលបត្របំណុលបានឡើយ[48] ៖

- អ្នកដាក់ពាក្យសុំ ឬការស្នើសុំសម្រាប់លក់មូលបត្របំណុលមានលក្ខណៈ ឬចនាសម្ព័ន្ធស្របតាមវិធាន ឬលក្ខខណ្ឌនៃការអនុម័តក្រោមសេចក្តីជូនដំណឹងនេះ ប៉ុន្តែអង្គហេតុជាក់លាក់នាំឱ្យមានការពិចារណាថាចេតនាពិត ឬខ្លឹមសារនៃការផ្តល់ជូនសម្រាប់ការលក់មូលបត្របំណុលបង្កើតជាការជៀសវាងនៃបទប្បញ្ញត្តិនៃច្បាប់មូលបត្រ និងសេចក្តីជូនដំណឹងនេះ
- ការស្នើសុំលក់មូលបត្របំណុលអាចផ្ទុយនឹងគោលនយោបាយសាធារណៈឬរដ្ឋាភិបាល។
- ការផ្តល់ជូនសម្រាប់ការលក់មូលបត្របំណុលអាចជះឥទ្ធិពលអវិជ្ជមានដល់ភាពជឿជាក់នៃទីផ្សារមូលធនថៃ។
- ការផ្តល់ជូននូវការលក់មូលបត្របំណុលអាចបណ្តាលឱ្យខូចខាតឬអយុត្តិធម៌ដល់វិនិយោគិនជាទូទៅ ឬវិនិយោគិនប្រហែលជាមិនបានទទួលព័ត៌មានត្រឹមត្រូវ ឬគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសម្រេចចិត្តវិនិ-យោគរបស់ពួកគេ។

ក្នុងករណីដែលមានព័ត៌មានបន្ថែមដែលការិយាល័យគណកម្មការមូលបត្របានដឹងបន្ទាប់ពីធ្វើការយល់ព្រមលើការបោះផ្សាយមូលបត្របំណុលបង្ហាញថា រាល់ពត៌មានទាំងនោះគណកម្មការមូលបត្របានប្រើក្នុងការពិចារណាលើការអនុម័តត្រូវបានផ្លាស់ប្តូរ ហើយប្រសិនបើគណកម្មការមូលបត្រត្រូវបានដឹងនៅការិយាល័យមូលបត្រមុនពេលមានការយល់ព្រមលើការផ្តល់ជូនសម្រាប់ការលក់នេះការិយាល័យ

[47] Section 74 Securities and Exchange Act B.E. 2535 (As Amended)

[48] Clause 10 of Notification of the Capital Market Supervisory Board No. Tor Jor. 17/2561 Re: Application and Approval for Offer for Sale of Newly Issued Debt Securities

គណកម្មការមូលបត្រមិនអាចផ្តល់ការយល់ព្រមសម្រាប់ការផ្តល់ជូនសម្រាប់លក់នោះទេ ការិយាល័យគណកម្ម-ការមូលបត្រមានសិទ្ធិអំណាចដើម្បី[49] ៖

១. បញ្ជាឱ្យអង្គភាពដែលត្រូវបានអនុម័ត ឬនាយក ឬនាយកប្រតិបត្តិរបស់ខ្លួនបំភ្លឺ ឬបង្ហាញព័ត៌មានបន្ថែមក្នុងរយៈពេលដែលបានកំណត់ និងព្យួរការអនុញ្ញាតលើការផ្តល់មូលបត្របំណុល ឬព្យួរការបោះផ្សាយមូលបត្របំណុលរហូតដល់មានការបញ្ជាក់ច្បាស់លាស់ ឬការកែតម្រូវត្រូវបានធ្វើឡើង ហើយប្រសិនបើអង្គភាពដែលត្រូវបានអនុម័ត ឬនាយក ឬនាយកប្រតិបត្តិខកខានមិនបានផ្តល់ការបំភ្លឺ ឬធ្វើការកែតម្រូវក្នុងរយៈពេលដែលបានកំណត់ការិយាល័យគណកម្មការមូលបត្រអាចដកហូតការអនុម័តបាន

២. ដកហូតការយល់ព្រមនៃការផ្តល់ជូនសម្រាប់លក់ចំណែកនៃបំណុលដែលមិនទាន់បានផ្តល់ជូនសម្រាប់លក់ ឬមិនទាន់ជាវ

ការិយាល័យគណកម្មការមូលបត្រ ត្រូវពិចារណាលើកត្តាដូចខាងក្រោមនេះ ៖

- .ភាពធ្ងន់ធ្ងរនៃព័ត៌មានដែលត្រូវបានផ្លាស់ប្តូរ
- ផលប៉ះពាល់លើវិនិយោគិនដែលបានជាវមូលបត្របំណុលទាំងនោះ

**ខ. ការយល់ព្រម និងផ្សាយពាណិជ្ជកម្ម**

នៅពេលដែលសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានក្លាយជាមានប្រសិទ្ធិភាព នោះសំណើលក់មូលបត្រជាសាធារណៈអាចត្រូវបានធ្វើឡើងតែនៅពេលដែលសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជីនិងសេចក្តីព្រាងការជូនព័ត៌មានត្រូវបានចែកចាយ[50] ។

បន្ទាប់ពីកាលបរិច្ឆេទដែលសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានក្លាយជាមានប្រសិទ្ធិភាព ការិយាល័យគណកម្មការមូលបត្រនឹងមានសិទ្ធិអំណាចដូចខាងក្រោមៈ

១. ក្នុងករណីដែលការិយាល័យគណកម្មការមូលបត្ររកឃើញថាសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានមានភាពមិនពិត ឬស្របតាមអង្គហេតុពិតប្រាកដ; ដែលអាចបង្កការខូចខាតដល់អ្នកទិញមូលបត្រការិយាល័យគណកម្មការមូលបត្រមានអំណាចបញ្ជាឱ្យព្យួរប្រសិទ្ធិភាពនៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាន និងក្នុងករណីដែលសំណើលក់មូលបត្រត្រូវបានអនុម័ត ការិយាល័យគណកម្មការមូលបត្រមានសិទ្ធិអំណាចបញ្ជាឱ្យព្យួរការអនុម័តនេះជាបន្ទាន់

[49] Clause 12 of Notification of the Capital Market Supervisory Board No. Tor Jor. 17/2561 Re: Application and Approval for Offer for Sale of Newly Issued Debt Securities

[50] Section 79 Securities and Exchange Act B.E. 2535 (As Amended)

២. ក្នុងករណីដែលការិយាល័យគណកម្មការមូលបត្ររកឃើញថា របាយការណ៍ ឬចំណុចមួយក្នុង សេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានមានភ្ជាប់នូវអង្គហេតុសំខាន់ៗដែលមិនត្រឹមត្រូវ ឬមានព្រឹត្តិការណ៍មួយដែលបណ្តាលឱ្យមានការផ្លាស់ព័ត៌មានសំខាន់ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានដែលអាចជះឥទ្ធិពលដល់ការសម្រេចចិត្តវិនិយោគរបស់អ្នកទិញមូលបត្រ,ការិយាល័យគណកម្មការមូលបត្រមានអំណាចបញ្ជាឱ្យផ្អាកជាបណ្តោះអាសន្ននូវប្រសិទ្ធិភាពនៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានរហូតដល់មានសកម្មភាពត្រូវបានធ្វើឡើងដើម្បីធ្វើការកែតម្រូវ ហើយនិងសកម្មភាពផ្សេងទៀតត្រូវធ្វើឡើងដោយគណកម្មការមូលបត្រដើម្បីធ្វើការកែប្រែព័ត៌មាននោះ ។

៣. ក្នុងករណីដែលការិយាល័យគណកម្មការមូលបត្ររកឃើញថា របាយការណ៍ ឬចំណុចណាមួយនៃសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មានមានភាពមិនត្រឹមត្រូវនៅក្នុងផ្នែកផ្សេងទៀត ការិយាល័យគណកម្មការមូលបត្រអាចបញ្ជាឱ្យអ្នកដាក់ពាក្យរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត; ក្រុមហ៊ុន ឬម្ចាស់មូលបត្រដែលដាក់ឯកសារធ្វើការកែតម្រូវ។

បទបញ្ជារបស់ការិយាល័យគណកម្មការមូលបត្រ មិនប៉ះពាល់ដល់សកម្មភាពរបស់អ្នកដាក់ពាក្យឡើយ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុន ឬម្ចាស់មូលបត្រដែលកាន់កាប់មុនពេលមានបទបញ្ជា និងមិនប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលណាមួយ ដែលអាចទាមទារសំណងឡើយ[51]។

ការផ្សាយពាណិជ្ជកម្ម និងការអញ្ជើញឱ្យសាធារណៈជន ឬមនុស្សណាមួយមកធ្វើបរិវិសកម្មមូលបត្រដោយអ្នកដាក់ពាក្យរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុន ឬម្ចាស់មូលបត្រដែលមិនអនុវត្តតាមនិតិវិធីអាចធ្វើទៅបាន លុះត្រាតែសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជីនិងសេចក្តីព្រាងការជូនព័ត៌មានក្លាយជាមានប្រសិទ្ធភាព និងមិនត្រូវមានសេចក្តីថ្លែងបំផ្លើសការនិយាយ; មិនពិត ឬការបំភាន់ឡើយ។ ក្នុងករណីដែលការផ្សព្វផ្សាយត្រូវបានធ្វើឡើងតាមមធ្យោបាយនៃការបោះពុម្ព; វាត្រូវមានព័ត៌មានលំអិតដូចខាងក្រោម[52] ៖

១. ចំនួន, ប្រភេទ, តម្លៃក្នុងមួយឯកតា និងតម្លៃមូលបត្រសរុប

២. ឈ្មោះអ្នកដាក់ពាក្យនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត; ក្រុមហ៊ុន ឬម្ចាស់ក្រុមហ៊ុនមូលបត្រ;

៣. ប្រភេទអាជីវកម្មដែលធ្វើ ឬកំពុងដំណើរការ។

៤. ទីកន្លែង និងពេលវេលាដែលអាចទទួលបានសេចក្តីព្រាងការជូនព័ត៌មាន។

៥. ឈ្មោះរបស់ភ្នាក់ងារធានាទិញមូលបត្រ (បើមាន)

---

[51] Section 76 Securities and Exchange Act B.E. 2535 (As Amended)

[52] Section 80 Securities and Exchange Act B.E. 2535 (As Amended)

៦. ចំណុចពិសេសផ្សេងទៀតដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាត្រួតពិនិត្យទីផ្សារ។

## ៤. ដំណាក់កាលក្រោយបោះផ្សាយ

បន្ទាប់ពីការបញ្ចប់នៃការលក់មូលបត្រអ្នកដាក់ពាក្យនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុន ឬម្ចាស់មូលបត្រត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការលក់ទៅការិយាល័យគណកម្មការមូលបត្រ។ ក្នុងករណីដែលសំណើលក់ត្រូវបានធ្វើឡើងតាមរយៈអ្នកធានាទិញលក់ អ្នកដាក់ពាក្យដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុន ឬម្ចាស់មូលបត្រត្រូវធ្វើរបាយការណ៍ពីចំនួនទឹកប្រាក់នៃមូលបត្រ និង ចំនួនទឹកប្រាក់ដែលបានទទួលសម្រាប់មូលបត្រដែលត្រូវបានទិញដោយក្រុមហ៊ុនធានាទិញមូលបត្រផងដែរ។

របាយការណ៍ដែលបានលើកឡើងនេះ ត្រូវធ្វើឡើងស្របតាមវិធាន និងនីតិវិធីដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងរបស់ការិយាល័យគណកម្មការមូលបត្រ[53] ។

ក្នុងករណីដែលសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីព្រាងការជូនព័ត៌មាន មានព័ត៌មានមិនពិត ឬមិនបានបង្ហាញអង្គហេតុសំខាន់ដែលគួរតែត្រូវបានបញ្ជាក់ អ្នកដែលទិញមូលបត្រពីអ្នកដាក់ពាក្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុន ឬម្ចាស់មូលបត្រដែលនៅតែជាម្ចាស់នៃមូលបត្រដែលទទួលរងការខូចខាតពីការទិញបែបនេះមានសិទ្ធិទាមទារសំណងពីក្រុមហ៊ុន ឬម្ចាស់មូលបត្រ។

បុគ្គលខាងក្រោមនេះត្រូវទទួលខុសត្រូវ រួមគ្នាជាមួយក្រុមហ៊ុន ឬម្ចាស់មូលបត្រលើកលែងតែបុគ្គលទាំងនោះអាចបង្ហាញថា ពួកគេមិនបានដឹងអំពីអង្គហេតុ ឬដោយសារមុខតួនាទីរបស់ពួកគេ ពួកគេមិនអាចដឹងអំពីភាពមិនពិតនៃព័ត៌មាន ឬការខកខានមិនបានបង្ហាញអង្គហេតុដែលត្រូវបញ្ជាក់៖

ក. អគ្គនាយកដែលមានអំណាចក្នុងការចាត់តាំងក្រុមហ៊ុន និងចុះហត្ថលេខាឈ្មោះរបស់ពួកគេនៅក្នុងឯកសារសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីជូនព័ត៌មាន

ខ. អ្នកពាក្យដាក់ពាក្យរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះហត្ថលេខាឈ្មោះរបស់ពួកគេក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីជូនព័ត៌មាន

គ. អ្នកធានាទិញមូលបត្រ សវនករ ទីប្រឹក្សាហិរញ្ញវត្ថុ ឬអ្នកវាយតម្លៃទ្រព្យសម្បត្តិដែលមានចេតនា ឬធ្វេសប្រហែសដែលបានចុះហត្ថលេខាឈ្មោះរបស់ពួកគេ ដើម្បីបញ្ជាក់ព័ត៌មាននៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការចុះបញ្ជី និងសេចក្តីជូនព័ត៌មាន។

[53] Section 81 Securities and Exchange Act B.E. 2535 (As Amended)

ក្រុមហ៊ុន ឬម្ចាស់មូលបត្រ និងបុគ្គលដែលបានលើកឡើងខាងលើ នឹងមិនទទួលខុសត្រូវក្នុងការបង់សំណងឡើយ ក្នុងករណីដូចខាងក្រោម ៖

១- អតិថិជនបានដឹង ឬគួរតែដឹងថាសេចក្តីថ្លែងការណ៍ ឬចំណុចណាមួយគឺមិនពិត ឬមានការខកខានក្នុងការបង្ហាញព័ត៌មានអង្គហេតុសំខាន់ដែលតម្រូវឱ្យមានបញ្ជាក់។

២- ការខូចខាតមិនបានកើតឡើងពីលទ្ធផលនៃការទទួលព័ត៌មានមិនពិត ឬការខកខានមិនបានបង្ហាញអង្គហេតុសំខាន់ដែលតម្រូវឲ្យមានបញ្ជាក់។

**កថាខណ្ឌទី ៣ ៖ ការចុះបញ្ជីលក់មូលបត្រចំណុលនៅផ្សារមូលបត្រថៃ**

**១. លក្ខណសម្បត្តិនៃសញ្ញាបណ្ណក្នុងការស្នើសុំចុះបញ្ជី**

សញ្ញាបណ្ណដែលអ្នកដាក់ពាក្យសុំសម្រាប់ការចុះបញ្ជីនៅផ្សារមូលបត្រ **(Stock Exchange of Thailand)** ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម[54] :

- តម្លៃស្នើសុំនៃសញ្ញាបណ្ណមិនតិចជាង ១០០,០០០,០០០ (មួយរយលាន) បាត;
- គឺជាសញ្ញាបណ្ណដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់ដោយទីភ្នាក់ងារទទួលបន្ទុកត្រួតពិនិត្យការបោះផ្សាយ និងសំណើលក់សញ្ញាបណ្ណទាំងនោះ ប៉ុន្តែសម្រាប់តែអ្នកបោះផ្សាយសញ្ញាបណ្ណណាដែលមានកាតព្វកិច្ចស្វែងរកការយល់ព្រមឲ្យបោះផ្សាយ និងធ្វើសំណើលក់សញ្ញាបណ្ណតែប៉ុណ្ណោះ ។

**២. លក្ខខណ្ឌ និងនីតិវិធីដែលចុះបញ្ជីលក់មូលបត្រ**

**ក. ការដាក់ពាក្យស្នើសុំ**

អ្នកដាក់ពាក្យសុំមានតួនាទីដូចតទៅ ៖

- ដាក់ពាក្យស្នើសុំចុះបញ្ជីសញ្ញាបណ្ណទាំងអស់ដែលត្រូវបានបោះផ្សាយ រាល់ពេលដាក់ពាក្យស្នើសុំ[55]
- អ្នកដាក់ពាក្យសុំត្រូវបំពេញពាក្យសុំ និងឯកសារផ្សេងទៀតដែលតម្រូវដោយផ្សារមូលបត្រ និងបង់ថ្លៃសេវាសម្រាប់ការដាក់ពាក្យសុំ[56]។

[54] Point 4 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[55] Point 5 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[56] Point 7 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

- អ្នកដាក់ពាក្យសុំដែលជាក្រុមហ៊ុនចុះបញ្ជីនេះអាចមិនដាក់ពាក្យស្នើសុំចុះបញ្ជីសញ្ញាបណ្ណជាសញ្ញាបណ្ណដែលបានចុះបញ្ជីឡើយ ក្នុងករណីដែលភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនចុះបញ្ជីណាមួយស្ថិតនៅក្នុងរយៈពេលមួយការហាមឃាត់មិនឱ្យទិញ ឬលក់មូលបត្រដែលបានចុះបញ្ជី ពីព្រោះក្រុមហ៊ុនដែលបានចុះបញ្ជីនេះគឺជាជួបប្រទះបញ្ហាណាមួយដូចខាងក្រោម[57] ៖

  ១. កំពុងស្ថិតក្នុងដំណើការនៃសំណងសម្រាប់ការលុបបំបាត់មូលដ្ឋាននៃដកភាគហ៊ុនធម្មតាចេញបន្ទាប់ពីការជូនដំណឹងពីការផ្សារមូលបត្រ

  ២. កំពុងដំណើរការតាមផែនរៀបចំឡើងវិញក្រោមច្បាប់ទាក់ទងនឹងការក្ស័យធន ឬ

  ៣. ដំណើរការដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិនិងផលប្រយោជន៍ម្ចាស់ភាគហ៊ុន។

ចំណុចដែលបានលើកឡើងខាងលើមិនត្រូវបានអនុវត្តចំពោះសញ្ញាបណ្ណដែលបោះផ្សាយដោយភ្នាក់ងារ រដ្ឋាភិបាល ឬសហគ្រាសរដ្ឋឡើយ។

**ខ. ការពិចារណាក្នុងការអនុញ្ញាតលើការបោះផ្សាយសញ្ញាបណ្ណ**

- ចំពោះផ្សារមូលបត្រ ៖ ក្នុងការពិចារណាលើពាក្យសុំ ផ្សារមូលបត្រអាចណែនាំឲ្យអ្នកដាក់ពាក្យស្នើសុំធ្វើរបាយការណ៍បន្ថែមណាមួយ ឬបញ្ជូនឯកសារបន្ថែមណាមួយ ឬភស្តុតាងដែលសមស្របក្នុងរយៈពេលដែលបានកំណត់[58]។ បន្ទាប់មក ក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់ការពិចារណាលើពាក្យសុំក្នុងរយៈពេល **៧** (ប្រាំពីរ) ថ្ងៃ ចាប់ពីថ្ងៃដែលផ្សារមូលបត្រទទួលបានឯកសារត្រឹមត្រូវ និងភស្តុតាងពេញលេញពីអ្នកដាក់ពាក្យសុំ[59] (រយៈពេលរវាងកាលបរិច្ឆេទដែលអ្នកដាក់ពាក្យស្នើសុំធ្វើការកែប្រែព័ត៌មាន ឬឯកសារ ឬកាលបរិច្ឆេទដែលផ្សារមូលបត្រផ្តល់ការណែនាំរហូតដល់កាលបរិច្ឆេទដែលផ្សារមូលបត្រទទួលបានព័ត៌មានត្រឹមត្រូវនិងពេញលេញ មិនត្រូវបានរាប់ឡើយ)។
- ចំពោះអ្នកដាក់ពាក្យសុំ ៖ ក្នុងអំឡុងពេលពិចារណាលើពាក្យសុំ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំធ្វើកែប្រែព័ត៌មាន ឬឯកសារណាមួយដែលបានដាក់ជូនផ្សារមូលបត្រ អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យស្នើសុំធ្វើការកែប្រែនៃភាពខុសគ្នា និងហេតុផលច្បាស់លាស់។ លើកលែងតែក្រុមប្រឹក្សាភិបាលកំណត់ថាអ្វីដែល

[57] Point 6 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[58] Point 13 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[59] Point 15 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

បានស្នើសុំធ្វើការកែប្រែគឺជាឯកសារសំខាន់ ក្រុមប្រឹក្សាភិបាលអាចចាត់ទុកការកែប្រែនេះទៅជាការដាក់ពាក្យជាថ្មី[60] ។

ក្នុងការពិចារណាលើការដាក់ពាក្យ និងការអនុញ្ញាតលើសញ្ញាបណ្ណនេះ ក្រុមប្រឹក្សាភិបាលអាចចាត់តាំងប្រធាននៃផ្សារមូលបត្រដើម្បីពិចារណាអំពីលក្ខណៈសម្បត្តិរបស់សញ្ញាបណ្ណ។ ប្រសិនបើប្រធាននៃផ្សារមូលបត្រ រកឃើញថាសញ្ញាបណ្ណនេះមានគុណវុឌ្ឍិស្របតាមវិធានលក្ខន្តិកៈ និងនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនេះ ប្រធាននៃផ្សារមូលបត្រ ត្រូវបញ្ជាឱ្យមានការអនុញ្ញាតឲ្យសញ្ញាបណ្ណនេះអាចចុះបញ្ជីជាមូលបត្រដែលបានចុះបញ្ជី[61]។

បន្ទាប់ពីពិចារណាលើពាក្យសុំដោយក្រុមប្រឹក្សាភិបាល ប្រសិនបើក្រុមប្រឹក្សារកឃើញថាសញ្ញាបណ្ណដែលបានដាក់ពាក្យសុំចុះបញ្ជីមានគុណសម្បត្តិត្រឹមត្រូវស្របតាមវិធាន និងលក្ខខណ្ឌនៃបទប្បញ្ញត្តិដែលមានចែង ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាឱ្យមានការអនុញ្ញាតឲ្យសញ្ញាបណ្ណនេះទៅជាមូលបត្រដែលបានចុះបញ្ជី។

នៅពេលបញ្ជាឱ្យមានការអនុញ្ញាតលើសញ្ញាបណ្ណរបស់អ្នកដាក់ពាក្យសុំដែលទទួលបានចុះបញ្ជីនៅផ្សារមូលបត្រ ក្រុមប្រឹក្សាភិបាលនឹងផ្តល់ឱ្យតាមលំដាប់ដូចគ្នាក្នុងពេលដំណាលគ្នាជាមួយ ឬបន្ទាប់ពីការអនុម័តនៃភាគហ៊ុនធម្មតាទៅជាមូលបត្រដែលបានចុះបញ្ជី ហើយអាចចេញនូវបញ្ញត្តិលក្ខខណ្ឌណាមួយដែលជាក្រុមប្រឹក្សាភិបាលចាត់ទុកថាសមរម្យ។ ការជួញដូរមូលបត្រដែលបានចុះបញ្ជី លើផ្សារមូលបត្រនឹងចាប់ផ្តើមក្នុងរយៈពេល **២** (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទដែលក្រុមប្រឹក្សាភិបាលអនុម័តអនុញ្ញាតឲ្យសញ្ញាបណ្ណនេះទៅជាមូលបត្រដែលបានចុះបញ្ជី[62] ។

អ្នកបោះផ្សាយសញ្ញាបណ្ណត្រូវប្រកាន់ខ្ជាប់នូវច្បាប់ស្តីពីមូលបត្រ បទប្បញ្ញត្តិ សេចក្តីជូនដំណឹងដំណោះស្រាយរបស់ក្រុមប្រឹក្សាភិបាល ឬកិច្ចព្រមព្រៀងចុះបញ្ជីក៏ដូចជាវិធានទាំងមូលរបស់ផ្សារមូលបត្រ[63]។

---

[60] Point 12 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[61] Point 14 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[62] Point 16 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

[63] Point 19 of "REGULATION OF THE STOCK EXCHANGE OF THAILAND"
Re: Listing of Debt Instruments as Listed Securities,2004

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី "**ក្របខណ្ឌគតិយុត្តស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈទាំងនៅក្នុងបរិបទប្រទេសកម្ពុជា និងបរិបទនៅក្នុងប្រទេសថៃ**" អាចឲ្យយើងកត់សម្គាល់ឃើញថា វិស័យមូលបត្រនៅប្រទេសទាំងពីរគឺមានគម្លាតហាក់ឆ្ងាយពីគ្នាបន្តិច ទាំងភាពសម្បូរបែបនៃឯកសារគតិយុត្តផ្សេងៗ ក៏ដូចជាទំហំទឹកប្រាក់នៃការវិនិយោគលើទីផ្សារមូលបត្រគឺនៅក្នុងប្រទេសថៃមានលក្ខណៈរីកចម្រើនខ្លាំងជាងប្រទេសកម្ពុជា។ តួយ៉ាង នៅកម្ពុជាគឺទើបតែដាក់ឲ្យដំណើរការនូវការបោះផ្សាយលក់សញ្ញាបណ្ណសាជីកម្មប៉ុណ្ណោះ មិនទាន់មានការដំណើរការការបោះផ្សាយលក់សញ្ញាបណ្ណដែលចេញដោយរដ្ឋ ឬបណ្ណរតនានៅឡើយទេ។ តែទោះជាយ៉ាងនេះក្តី ក៏វាមិនមែនជាបញ្ហាចោទសម្រាប់វិស័យមូលបត្រប្រទេសកម្ពុជាដែរ ព្រោះវត្តមាននៃមូលបត្របំណុលនៅក្នុងបរិបទប្រទេសកម្ពុជាគឺមានលក្ខណៈនៅថ្មីថ្មោងនៅឡើយ ពោលគឺក្រុមហ៊ុនសារជីវកម្មដំបូងដែលបានបោះផ្សាយលក់មូលបត្របំណុលទៅកាន់វិនិយោគិនជាសាធារណៈទើបបានចាប់ផ្តើមនាឆ្នាំ ២០១៨ នេះប៉ុណ្ណោះ គឺមានរយៈពេលខ្លីមែនទែន បើធៀបនឹងប្រទេសថៃដែលមានវត្តមានវិស័យមូលបត្រនេះជិតមួយសតវត្សទៅហើយ ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បាននឹងកំពុងជំរុញនូវការអភិវឌ្ឍវិស័យមូលបត្រនេះយ៉ាងសកម្ម ដែលឆ្លុះបញ្ចាំងឲ្យយើងបានឃើញតាមរយៈសកម្មភាពយ៉ាងឥតស្រាក់ស្រាន្តរបស់គណកម្មការមូលបត្រកម្ពុជា ( គ.ម.ក ) ក្នុងការធ្វើយ៉ាងណាដើម្បីបង្កើតនូវវិធានគតិយុត្តនានាសម្រាប់ប្រើប្រាស់ឲ្យបានទូលំទូលាយ ក៏ដូចជាការព្យាយាមទាក់ទាញវិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុកឲ្យមកវិនិយោគ ដោយខិតខំកសាងនូវទំនុកចិត្តដល់វិនិយោគិនទាំងនោះ រួមទាំងការការពារសិទ្ធ និងផលប្រយោជន៍របស់អ្នកវិនិយោគ ជួយសម្រួលនូវរាល់គ្រប់មធ្យោបាយទាំងអស់ក្នុងគោលដៅធ្វើយ៉ាងណាឲ្យពួកគេមានទំនុកចិត្តក្នុងការយកប្រាក់មកបណ្តាក់ទុនជាមួយវិស័យមូលបត្រកម្ពុជាដែលទើបនឹងមានវត្តមាននេះ ។ ប្រសិនបើការវិនិយោគវិស័យមូលបត្របំណុលនេះមានការរីកចម្រើនខ្លាំងកាលនោះ នោះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងក៏នឹងកាន់តែប្រសើរទៅមុខផងដែរ ព្រោះក្រុមហ៊ុនទាំងឡាយនឹងទទួលបានដើមទុនបន្ថែម ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន ក៏ដូចជាដូចបង្កើនការងារដល់ប្រជាពលរដ្ឋផងដែរ។ ជាក់ស្តែងនេះពលរដ្ឋមួយចំនួនចាប់ផ្តើមស្គាល់ឡើយថាអ្វីទៅជាមូលបត្រ ហើយតទៅនាពេលខាងមុខដ៏ខ្លីនេះពួកគាត់នឹងអាចក្លាយជាតួអង្គមួយនៃប្រតិបត្តិការជួញដូរមូលបត្រក៏ថាបាន ។ ដំណើរទៅមុខយ៉ាងវិជ្ជមាននៃវិស័យមូលបត្រកម្ពុជា ក្រោមការខិតខំប្រឹងប្រែងពីគ្រប់ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ យើងមានសុទិដ្ឋិនិយមថាវិស័យមូលបត្ររបស់កម្ពុជានឹងមានការអភិវឌ្ឍទៅមុខយ៉ាងឆាប់រហ័ស ទាំងមានភាពសម្បូរបែបនៃឯកសារគតិយុត្តនានានិងទំហំទឹកប្រាក់ក្នុងការវិនិយោគកាន់តែកើនឡើងជាលំដាប់។

# ឯកសារយោង


- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ប្រកាសស្តីពី ការបោះផ្សាយមូលបត្រប័ណ្ណលជាសាធារណៈ
- ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រប័ណ្ណលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- Exchange Act B.E. 2535 (As Amended)
- Regulation of the Stock Exchange of Thailand

  Re: Listing of Debt Instruments as Listed Securities,2004
- Notification of the Capital Market Supervisory Board No. Tor Jor. 17/2561

  Re: Application and Approval for Offer for Sale of Newly Issued Debt Securities
- Thai Bond Market Guide
- https://www.bot.or.th/English/DebtSecurities/IntroToGovtDebtSecurities/Pages/default.aspx
- https://www.lexology.com/library/detail.aspx?g=ef4650cf-9ef5-4170-92a0-2a872d22d60e